# សៀវភៅណែនាំអនុវត្តការងារ

## សម្រាប់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង
# ប្រធានកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជា

សៀវភៅណែនាំ ស្តីពីការសម្រុះសម្រួល និងប្រតិបត្តិការសម្រាប់មណ្ឌលសេវាកម្មយុត្តិធម៌ស្រុក ក្រុង និងគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ក្នុងគម្រោងសាកល្បងនេះ កើតចេញពីការខិតខំប្រឹងប្រែងរបស់គម្រោងសិទ្ធិទទួលបានយុត្តិធម៌ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលអនុវត្តដោយក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ក្រោមជំនួយឧបត្ថម្ភពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) និងទីភ្នាក់ងារអេស្ប៉ាញសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការអភិវឌ្ឍន៍(AECID) ក្នុងទិសដៅលើកកម្ពស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ នេះជាគោលដៅទី៦ ក្នុងចំណោមគោលដៅដ៏ចម្បងទាំងប្រាំពីរ នៃកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងដំណាក់កាលទីពីរ ដែលរួមមាន : ១-ពង្រឹងការការពារសិទ្ធិ និងសេរីភាពបុគ្គល ២-ធ្វើទំនើបកម្មក្របខណ្ឌច្បាប់ ៣-ផ្តល់លទ្ធភាពឱ្យទទួលបាននូវព័ត៌មានអំពីច្បាប់ និងយុត្តិធម៌កាន់តែប្រសើរឡើង ៤-ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃដំណើរការក្តី និងសេវាកម្មដែលពាក់ព័ន្ធ ៥-ពង្រឹងសេវាកម្មយុត្តិធម៌ គឺអំណាចតុលាការ និងសេវាកម្មផ្នែកអយ្យការ ៦-បញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ៧-ពង្រឹងស្ថាប័នវិស័យយុត្តិធម៌ ឱ្យបំពេញអណត្តិរបស់ខ្លួនបានសំរេច។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅក្នុងដំណាក់កាលនៃការអនុវត្តន៍ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ ដោយប្រគល់នូវភាពជាម្ចាស់លើមុខងារ លើអំណាច ការទទួលខុសត្រូវ និងធនធាន រួមមានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកទៅអោយក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ដូចជា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ដើម្បីធ្វើការឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅតាមមូលដ្ឋាន ដោយធានាបាននូវការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

សៀវភៅណែនាំ និងប្រតិបត្តិការនេះ ចងក្រងឡើងដោយមន្ត្រីជំនាញរបស់គម្រោងសិទ្ធិទទួលបានយុត្តិធម៌ ដែលមានក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ដែលកើតចេញពីការអនុវត្តន៍ដោយផ្ទាល់នៅមូលដ្ឋានថ្នាក់ក្រោមជាតិ នូវយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅក្នុងខេត្ត ចំនួន៦ រួមមាន : ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរី។ គម្រោងនេះ បានបង្កើតមណ្ឌលសេវាកម្មយុត្តិធម៌ស្រុក ក្រុង ចំនួន២០ និងគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ចំនួន៥៦ នៅក្នុងគម្រោង សាកល្បង។ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ មានបំណងប្រាថ្នាចង់ដាក់គម្រោងនេះឱ្យអនុវត្តនៅទូទាំងប្រទេស។ ដោយហេតុផលនេះ គម្រោងបានរៀបចំសៀវភៅណែនាំនេះឡើងសម្រាប់មណ្ឌល ...

សេវាកម្មយុត្តិធម៌ស្រុក ក្រុង និងគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ប្រើប្រាស់នៅក្នុងការអនុវត្តការសម្រុះសម្រួលទំនាស់ នៅតាមមូលដ្ឋាន។

ខ្លឹមសារនៃសៀវភៅណែនាំនេះ ជាឯកសារមួយសម្រាប់អនុវត្តការងារប្រចាំថ្ងៃរបស់មណ្ឌលសេវាកម្មយុត្តិធម៌ស្រុក ក្រុង និងគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ នៅខណៈដែលសៀវភៅណែនាំស្តីពីការសម្រុះសម្រួល បង្ហាញអំពីដំណើរការនៃការសម្រុះសម្រួលទូទៅ។ ជាការពិតណាស់ ការអនុវត្តការសម្រុះសម្រួលនៅតាមមណ្ឌលសេវាកម្មយុត្តិធម៌ស្រុក ក្រុង និងគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ គឺមិនដូចគ្នាទៅនឹងការវិនិច្ឆ័យសេចក្តីដែលអនុវត្តដោយប្រព័ន្ធតុលាការទេ ដែលចៅក្រមជាអ្នកសម្រេចលើរឿងក្តី និងចេញសេចក្តីសម្រេចដែលចងភ្ជាប់កាតព្វកិច្ចដល់គូភាគី។ ដោយឡែកនៅក្នុងការសម្រុះសម្រួល អ្នកសម្រុះសម្រួលជួយភាគីដើម្បីធ្វើការពិភាក្សាលើបញ្ហារបស់ពួកគេ ក្នុងគោលបំណងដើម្បីឈានដល់កិច្ចព្រមព្រៀងមួយដែលភាគីទាំងសងខាងអាចទទួលយកបានដោយស្ម័គ្រចិត្ត។

សៀវភៅណែនាំ និងប្រតិបត្តិការនេះ មានគោលដៅជួយដល់ការងារប្រចាំថ្ងៃរបស់មន្ត្រីមណ្ឌលសេវាកម្មយុត្តិធម៌ស្រុក ក្រុង និងសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ និងផ្តល់នូវប្រភពព័ត៌មានស្តីពីការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនៅកម្ពុជានៅថ្នាក់រដ្ឋបាលក្រោមជាតិ ថែមទាំងជួយដោះបន្ទុក ដល់ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាស្រុក ក្រុង គណៈអភិបាលស្រុក ក្រុង និងក្រុមប្រឹក្សាឃុំ សង្កាត់។ ឯកសារនេះ មិនមែនជាបទដ្ឋានគតិយុត្តដែលមានលក្ខណៈដាច់ខាត និងដាក់កម្រិតត្រូវតែអនុវត្តតាមទាំងស្រុងនោះទេ។ ឯកសារនេះ ជាឯកសារជំនួយស្មារតីសម្រាប់ការណែនាំដល់អ្នកអនុវត្តន៍ផ្ទាល់លើការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ និងជាប្រភពព័ត៌មានសម្រាប់អាជ្ញាធរថ្នាក់ជាតិ ថ្នាក់រដ្ឋបាលក្រោមជាតិ អ្នកធ្វើគោលនយោបាយ និស្សិតច្បាប់ មេធាវី និងអ្នកដែលមានបំណងចង់សិក្សាស្វែងយល់ពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ មានជំនឿយ៉ាងមុតមាំថា ការចងក្រងសៀវភៅណែនាំនេះឡើង នឹងផ្តល់នូវគោលការណ៍អនុវត្តជាក់ស្តែង និងវិធីសាស្ត្រនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលអនុវត្តន៍ដោយថ្នាក់រដ្ឋបាលក្រោមជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

រាជធានីភ្នំពេញ, ថ្ងៃទី ..២៥..... ខែ ..កុម្ភៈ.....ឆ្នាំ ២០១០

**ជ.រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**រដ្ឋលេខាធិការ**

**ឯកឧត្តម នុត សាអាន**

**រដ្ឋមន្ត្រី**
**ក្រសួងយុត្តិធម៌**

**ឯកឧត្តម អង្គ វង្សវឌ្ឍានា**

**អនុប្រធានកម្មវិធីអភិវឌ្ឍន៍**
**សហប្រជាជាតិប្រចាំកម្ពុជា**

**Ms. Sophie Baranes**

សៀវភៅណែនាំ អំពីការសម្រុះសម្រួល និងប្រតិបត្តិការសម្រាប់មណ្ឌលសេវាកម្មយុត្តិធម៌ស្រុក ក្រុង និងគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ត្រូវបានចងក្រងឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៅមូលដ្ឋាន អំពីយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ក្រោមជាតិ។ សៀវភៅណែនាំនេះ បង្ហាញអំពីបច្ចេកទេស និងដំណើរការអនុវត្តការសម្រុះសម្រួលនៅមណ្ឌលសេវាកម្មយុត្តិធម៌ស្រុក ក្រុង និងគណៈ-កម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ដែលបានបង្កើតឡើង ក្រោមគម្រោងសាកល្បងនៃគម្រោងសិទ្ធិទទួលបានយុត្តិធម៌ ក្រោមជំនួយឧបត្ថម្ភពីទីភ្នាក់ងារអេស្ប៉ាញសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការអភិវឌ្ឍន៍ (AECID) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)។

សមាជិកក្រុមចងក្រងសៀវភៅណែនាំនេះ រួមមាន ឯកឧត្តម ផុន ប៊ុនថាល់ ប្រធានក្រុមប្រឹក្សានីតិកម្ម និងជាអ្នកសម្របសម្រួលថ្នាក់ជាតិ គម្រោងសិទ្ធិទទួលបានយុត្តិធម៌នៃក្រសួងមហាផ្ទៃ ឯកឧត្តម ផូវ សំភី អគ្គនាយកនៃនាយកដ្ឋានស្រាវជ្រាវអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ និងជាអ្នកសម្របសម្រួលថ្នាក់ជាតិ គម្រោងសិទ្ធិទទួលបានយុត្តិធម៌នៃក្រសួងយុត្តិធម៌ លោក ប៊ុនយ៉ៃ ណារិន អគ្គនាយករង នៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងជាអនុប្រធានគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៃក្រសួងយុត្តិធម៌ លោក សុខ បូរ៉ា អនុប្រធាននាយកដ្ឋានអប់រំ និងផ្សព្វផ្សាយច្បាប់ និងជាប្រធានគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៃក្រសួងយុត្តិធម៌ លោក មុនី វីរៈ សមាជិកក្រុមប្រឹក្សានីតិកម្ម និងជាប្រធានគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៃក្រសួងមហាផ្ទៃ លោក មាស សាវ៉ាត អ្នកសម្របសម្រួលការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ គម្រោងសិទ្ធិទទួលបានយុត្តិធម៌នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងកញ្ញា ជា សំរេច អ្នកសម្របសម្រួលការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ គម្រោងសិទ្ធិទទួលបានយុត្តិធម៌នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ។ ក្រុមមន្ត្រីជំនាញនៃគម្រោងសិទ្ធិទទួលបានយុត្តិធម៌ ដែលមានក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ សូមថ្លែងអំណរគុណដល់ការចូលរួមដ៏មានតម្លៃរបស់មន្ត្រីមណ្ឌលសេវាកម្មយុត្តិធម៌ស្រុក ក្រុង លោកអភិបាល អភិបាលរងស្រុក ក្រុង ទាំង ២០ និងសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ទាំង ៥៦ ក្នុងគម្រោងសាកល្បង ដែលស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរី ដែលបានអនុវត្តសាកល្បង និងបានចូលរួមផ្តល់គំនិតយោបល់ដើម្បីកែលំអសៀវភៅណែនាំនេះ។

ក្រុមអ្នកចងក្រងសៀវភៅណែនាំនេះ សូមសំដែងអំណរគុណចំពោះ លោក កុយ នាម អតីតប្រធានគម្រោងសិទ្ធិទទួលបានយុត្តិធម៌ កញ្ញា Lise Dahl អតីតអ្នកជំនាញផ្នែកច្បាប់ លោក គង់ រ៉ាឌី អតីតអ្នកជំនាញផ្នែកច្បាប់ជាតិ និងលោក ហុង សុខខេង អតីតអ្នកសម្របសម្រួលការដោះស្រាយទំនាស់ក្រៅប្រព័ន្ធ តុលាការ គម្រោសិទ្ធិទទួលបានយុត្តិធម៌នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ដែលបានផ្តើមគំនិតចងក្រងសៀវភៅណែនាំប្រតិបត្តិការសម្រាប់មណ្ឌលសេវាកម្មយុត្តិធម៌នៅដំណាក់កាលដំបូង។

យើងសូមថ្លែងអំណរគុណដល់បុគ្គលិកគម្រោងសិទ្ធិទទួលបានយុត្តិធម៌ ចំពោះការខិតខំប្រឹងប្រែងចូលរួមផ្ដល់នូវគំនិតយោបល់ល្អៗ និងធ្វើការកែលំអទាំងពាក្យពេចន៍ និងខ្លឹមសារ ជាពិសេស លោកស្រី Dorine van der Keur អ្នកសម្របសម្រួលអន្តរជាតិ គម្រោងសិទ្ធិទទួលបានយុត្តិធម៌នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានត្រួតពិនិត្យ និងកែសម្រួលបច្ចេកទេស និង កញ្ញា Arezo Malakooti អ្នកជំនាញផ្នែកច្បាប់ គម្រោងសិទ្ធិទទួលបានយុត្តិធម៌នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានកែសម្រួលអក្ខរាវិរុទ្ធនៅក្នុងអត្ថបទភាសាអង់គ្លេស និង លោក ពៅ វីបុល មន្ត្រីគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៃក្រសួងយុត្តិធម៌ ដែលបានជួយត្រួតពិនិត្យអក្ខរាវិរុទ្ធនៅក្នុងអត្ថបទជាភាសាខ្មែរ ដើម្បីធ្វើអោយសៀវភៅណែនាំនេះ មានគុណភាពកាន់តែប្រសើរឡើង។

បន្ថែមពីលើនេះទៅទៀត យើងសូមអរគុណចំពោះទីភ្នាក់ងារអេស្ប៉ាញសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការអភិវឌ្ឍន៍ (AECID) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំនៅកម្ពុជា ដែលបានគាំទ្រហិរញ្ញវត្ថុចំពោះការបោះពុម្ពសៀវភៅណែនាំនេះ។

| | |
|---|---|
| ADR | ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ |
| CDRC | គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ (គដទឃ) |
| DV Law | ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ |
| Maison | មណ្ឌលសេវាកម្មយុត្តិធម៌ស្រុក ក្រុង (មសយ) |
| MoI | ក្រសួងមហាផ្ទៃ |
| MoJ | ក្រសួងយុត្តិធម៌ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |

គោលបំណងរបស់សៀវភៅណែនាំ.............................................................................ix
វិសាលភាពនៃសៀវភៅណែនាំ.................................................................................ix
ជំពូកទី ១ : គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់........................................................ ១
១.១ ទិសដៅរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ........................................... ១
១.២ គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ .............................................................. ១
១.៣ តួនាទី និង ភារកិច្ចរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់............................ ២
ជំពូកទី ២ : គោលការណ៍ និងក្រមសីលធម៌ ...........................................................................៣
២.១ គោលបំណងនៃក្រមសីលធម៌ .........................................................................................៣
២.២ គោលការណ៍ជាគន្លឹះ និងក្រមសីលធម៌ .........................................................................៣
*២.២.១ ការរក្សាភាពសម្ងាត់.................................................................................................៣*
*២.២.២ ការរក្សាទុកឯកសារ និងការប្រើប្រាស់ព័ត៌មាន .............................................................៣*
*២.២.៣ ជំនឿទុកចិត្ត...........................................................................................................៤*
*២.២.៤ សមធម៌ យុត្តិធម៌ និងសិទ្ធិមនុស្ស..............................................................................៤*
*២.២.៥ ការរើសអើង ...........................................................................................................៤*
*២.២.៦ យេនឌ័រ..................................................................................................................៤*
*២.២.៧ ទំនាស់ផលប្រយោជន៍ ...............................................................................................៥*
ជំពូកទី ៣ : នីតិវិធីនៃការសម្រុះសម្រួល...............................................................................៦
៣.១ នីតិវិធីនៃការសម្រុះសម្រួល..........................................................................................៦
*៣.១.១ ការទទួលពាក្យបណ្តឹង...............................................................................................៦*
*៣.១.២ សិទ្ធិក្នុងការជ្រើសរើសអ្នកសម្រុះសម្រួលដោយគូភាគី ...................................................៦*
*៣.១.៣ ការកំណត់កាលបរិច្ឆេទ និងទីកន្លែង ដើម្បីធ្វើការសម្រុះសម្រួល ...................................៧*
៣-២. ដ្យាក្រាមនៃនីតិវិធីសម្រុះសម្រួលនៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់.......................៨
៣.៣. ការដាក់ពាក្យបណ្តឹងនៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់.....................................៩
ជំពូកទី ៤ : ការគ្រប់គ្រងសំណុំរឿងនៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់.......................១៥
៤.១. ការសំគាល់ ការចុះបញ្ជី ការដាក់លេខរៀងសំណុំរឿងនៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ......១៥
*៤.១.១ ការសំគាល់សំណុំរឿង.............................................................................................១៦*
*៤.១.២ ការចុះបញ្ជីសំណុំរឿង..............................................................................................១៧*
*៤.១.៣ ការដាក់លេខរៀងសំណុំរឿង ....................................................................................១៨*
*៤.១.៤ ការបង្កើតប្រអប់សំណុំរឿង.......................................................................................១៨*

ជំពូកទី ៥ : ការទទួលសំណុំរឿងពិសេស ..... ២១
៥.១ ការកំណត់សំណុំរឿងដែលអាចធ្វើការសម្រុះសម្រួលបាន ..... ២១
៥.២ ការសម្រុះសម្រួលលើរឿងលែងលះ ..... ២២
៥.៣ ការសម្រុះសម្រួលសំណុំរឿងអំពើហិង្សាក្នុងគ្រួសារ ..... ២៣
៥.៤ សំណុំរឿងទាក់ទិនទៅនឹងយេនឌ័រ ..... ២៦
*៥.៤.១ និយមន័យ យេនឌ័រ ..... ២៦*
*៥.៤.២ ការពិចារណាទៅលើយេនឌ័រក្នុងការអនុវត្តជាក់ស្តែង ..... ២៧*
*៥.៤.៣ សិទ្ធិស្ត្រី គឺជាសិទ្ធិមនុស្ស ..... ២៨*
*៥.៤.៤ ផ្នែកយេនឌ័រ-ឯកសារច្បាប់នានា ..... ៣០*

ជំពូកទី ៦ : បច្ចេកទេស និងគោលការណ៍នៃការសម្រុះសម្រួល ..... ៣១
៦.១ ខ្លឹមសារទូទៅ ..... ៣១
៦.២ ការសម្រុះសម្រួលនៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ..... ៣២
៦.៣ កំហុសឆ្គងសាមញ្ញៗដែលត្រូវចៀសវាង ..... ៣៥
៦.៤ យុទ្ធសាស្ត្រការពារការកើនឡើងនៃទំនាស់រវាងភាគី ..... ៣៦
៦.៥. ជំនាញផ្សេងៗដែលជាគន្លឹះសម្រាប់ការសម្របសម្រួល ..... ៣៧
៦.៦ ការប្រឈមមុខចម្បងៗក្នុងការសម្រុះសម្រួលរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ..... ៣៨
៦.៧ ក្រមសីលធម៌នៃការសម្រុះសម្រួល ..... ៣៩

ជំពូកទី៧ : បែបបទនៃការរៀបចំឯកសារ ដើម្បីដំណើរការសម្រុះសម្រួល ..... ៤០
៧.១ សៀវភៅកំណត់ត្រាសំណុំរឿងរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ..... ៤១
៧.២ ទម្រង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង ..... ៤២
៧.៣ ទម្រង់បង្កាន់ដៃទទួលពាក្យបណ្តឹង ..... ៤៣
៧.៤ ទម្រង់លិខិតជូនដំណឹងរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ..... ៤៤
៧.៥ ទម្រង់កិច្ចព្រមព្រៀងចូលរួមក្នុងការសម្រុះសម្រួល ..... ៤៥
៧.៦ ទម្រង់កំណត់ហេតុនៃការសម្រុះសម្រួល ..... ៤៦
៧.៧ ទម្រង់កិច្ចព្រមព្រៀងនៃការសម្រុះសម្រួល ..... ៤៨

ជំពូកទី ៨ : ការរៀបចំរបាយការណ៍សកម្មភាពរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ..... ៥១
៨.១ ទម្រង់ និងខ្លឹមសារនៃការធ្វើរបាយការណ៍ ..... ៥១
៨.២ របាយការណ៍ស្ថិតិតួលេខ ..... ៥១
៨.៣ របាយការណ៍ពិពណ៌នា ..... ៥៤

# គោលបំណងរបស់សៀវភៅណែនាំ

សៀវភៅណែនាំនេះ ត្រូវបានចងក្រងឡើងសម្រាប់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ដោយផ្តល់ដល់ពួកគេទាំងអត្ថន័យ និងគោលការណ៍អនុវត្តជាក់ស្តែង សម្រាប់ដំណើរការការងារប្រចាំថ្ងៃរបស់គណៈ-កម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់។ ដោយមើលឃើញនូវភាពខ្វះចន្លោះជាក់ស្តែង ដែលកើតមានឡើងនៅក្នុងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជានាពេលបច្ចុប្បន្ននេះ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ រួមជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ មានបំណងផ្តល់នូវជម្រើសនៃការដោះស្រាយទំនាស់ក្រៅប្រព័ន្ធ ដែលងាកចេញពីតុលាការ ឬស្ថាប័នវិនិច្ឆ័យផ្សេងទៀត តាមរយៈការបង្កើតឡើងនូវគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ដែលផ្តល់សេវាកម្មសម្រុះសម្រួលទំនាស់មួយដែលមានតម្លាភាព។

ដោយមានការរំពឹងទុកថា សមាជិកគណៈកម្មាធិការដោះស្រាយវិវាទឃុំ សង្កាត់ទាំងអស់ គួរអានសៀវភៅណែនាំអនុវត្តការងារនេះដោយយកចិត្តទុកដាក់ និងប្រើប្រាស់ជាឯកសារយោង ព្រមទាំងពិនិត្យទៅលើគោលការណ៍នានានៅក្នុងសៀវភៅនេះ អោយបានទៀងទាត់នៅក្នុងពេលបំពេញតួនាទីរបស់ខ្លួនប្រចាំថ្ងៃ។

# វិសាលភាពនៃសៀវភៅណែនាំ

សៀវភៅណែនាំនេះឆ្លើយតបទាំងទៅលើទិដ្ឋភាពអត្ថន័យ និងនីតិវិធីនៃការងាររបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់។ នៅក្នុងសៀវភៅ ក៏បានរួមបញ្ចូលនូវគោលការណ៍ណែនាំមួយដំណាក់កាលម្តងៗ អំពីដំណើរការសម្រុះសម្រួល យេនឌ័រ ដំណើរការចុះបញ្ជី និងក្រមសីលធម៌របស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់។ នៅក្នុងសៀវភៅណែនាំនេះ ក៏បានរួមបញ្ចូលនូវឯកសារបន្ថែមទាក់ទងនឹងច្បាប់ជាតិ និងអន្តរជាតិ និងធនធានច្បាប់ ព្រមទាំងទម្រង់គំរូនៃនីតិវិធីនានា ដែលត្រូវប្រើប្រាស់ដោយគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ផងដែរ។ ធនធានផ្នែកច្បាប់ដែលភ្ជាប់មកជាមួយនេះ ក៏ផ្តល់ជាឯកសារយោងផ្នែកច្បាប់សម្រាប់សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ប្រើប្រាស់សម្រាប់ការផ្តល់ជាគំនិតយោបល់ផ្នែកផ្លូវច្បាប់ដល់ភាគីជម្លោះផងដែរ។ ក្នុងពេលដែលគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ត្រូវធ្វើការពង្រីកបន្ថែមទៀតនៅទូទាំងប្រទេស ករណីថ្មីៗនឹងកើតមានឡើង ហើយប្រសិនបើមានការចាំបាច់ផ្នែកផ្សេងៗទៀត អាចត្រូវបានបន្ថែមទៅលើសៀវភៅណែនាំនេះ។

# ១ គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ត្រូវបានបង្កើតឡើងដោយយោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១ និងប្រកាសអន្តរក្រសួង រវាងក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា លេខ ៨៥/០៦ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៦ និងលេខ ១៣/០៨ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨។ ខាងក្រោមនេះ ជាដំណើរការដោយសង្ខេបនៃការបង្កើតគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ និងមានរួមបញ្ចូលនូវទិសដៅ និងតួនាទីរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ផងដែរ។

## ១.១ ទិសដៅរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

ទិសដៅរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

- កាត់បន្ថយស្ថានភាពទំនាស់ និងគ្រប់គ្រងទំនាស់ដែលកើតមាននៅតាមមូលដ្ឋាន។
- ធ្វើការសម្រុះសម្រួលទំនាស់ក្នុងករណីមានការព្រមព្រៀងពីភាគីទំនាស់។
- ផ្សព្វផ្សាយព័ត៌មានផ្នែកច្បាប់ដែលចាំបាច់ដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។
- ផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ និងចង្អុលបង្ហាញនីតិវិធីបន្តដល់ភាគីទំនាស់ក្នុងករណីទំនាស់មិនអាចដោះស្រាយបាន ឬភាគីទំនាស់មិនមានបំណងដោះស្រាយនៅថ្នាក់មូលដ្ឋាន។
- ជួយសម្រួលដល់ការងារដោះស្រាយទំនាស់របស់ឃុំ សង្កាត់

## ១.២ សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

### ១.២.១ សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

គណៈកម្មាធិការមានសមាជិកចំនួន ៧ នាក់ ដែលក្នុងនោះ មានស្ត្រីយ៉ាងតិច ២ នាក់ រួមមាន ៖

| | | |
|---|---|---|
| - សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | ១ រូប | ជាប្រធាន |
| - ជនបង្គោលនារីឃុំ | ១ រូប | ជាអនុប្រធាន |
| - ប្រធាន ឬអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ | ១ រូប | ជាសមាជិក |
| - ប្រជាជនដែលមានកិត្តិយស និងការគោរពរាប់អាន ឬមានឥទ្ធិពលក្នុងឃុំ សង្កាត់ | ៤ រូប | ជាសមាជិក |

### ១.២.២ នីតិវិធីក្នុងការជ្រើសរើសសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

*ក. លក្ខណៈសម្បត្តិរបស់សមាជិកគណៈកម្មាធិការ*

- អាយុយ៉ាងតិច ២៥ ឆ្នាំ
- ចេះអាន និងចេះសរសេរ
- មានឆន្ទៈធ្វើការដើម្បីសហគមន៍
- មានសីលធម៌សង្គមថ្លៃថ្នូរ
- មានកេរ្តិ៍ឈ្មោះ និងមានប្រជាប្រិយភាពនៅក្នុងភូមិ
- មានលំនៅដ្ឋាននៅក្នុងឃុំគោលដៅ

*ខ. នីតិវិធីក្នុងការជ្រើសរើសសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់*

*ខ.១. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ :* ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបោះឆ្នោតជ្រើសរើសសមាជិកម្នាក់ អោយធ្វើជាប្រធាន និងម្នាក់ទៀត ជាអនុប្រធានគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

*ខ.២. នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ :* ប្រធាននគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ ត្រូវស្នើបេក្ខភាពម្នាក់ ដើម្បីអោយក្រុមប្រឹក្សាឃុំ សង្កាត់ បោះឆ្នោត

*ខ.៣. ប្រជាជនដែលមានកិត្តិយស ការគោរពរាប់អាន និងមានឥទ្ធិពល នៅក្នុងឃុំ សង្កាត់ :* ក្រោមការជួយជ្រោមជ្រែងពីអាជ្ញាធរឃុំ សង្កាត់ និងស្រុក ក្រុង ភូមិនីមួយៗ នឹងរៀបចំអោយមានការបោះឆ្នោតជ្រើសរើសយកបេក្ខភាពចំនួន ២ រូប (ប្រុសម្នាក់ និងស្រីម្នាក់) រួចហើយបញ្ជូនសមាភាពរបស់ពួកគេទៅកាន់ឃុំ សង្កាត់ បន្ទាប់មក ក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវធ្វើការបោះឆ្នោតជ្រើសរើសសមាសភាពទាំង ៤ រូប ចេញពីក្នុងបេក្ខភាពដែលបានជាប់ឆ្នោតតំណាងឱ្យប្រជាពលរដ្ឋមកពីភូមិនីមួយៗ។ អ្នកឈ្នះនៅក្នុងការបោះឆ្នោតក្នុងភូមិ នឹងត្រូវប្រកួតជាបេក្ខជន ដែលឈ្នះឆ្នោតមកពីភូមិផ្សេងទៀតនៅក្នុងឃុំ សង្កាត់របស់ពួកគេ។ បេក្ខជនទាំងអស់ដែលបានជ្រើសរើស នឹងត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីធ្វើការជ្រើសរើសជាចុងក្រោយ ។

## ១.៣ តួនាទី និងភារកិច្ចរបស់សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

- សម្រុះសម្រួលរាល់វិវាទរដ្ឋប្បវេណី តាមគោលការណ៍ស្ម័គ្រចិត្តរបស់គូភាគី
- សម្រុះសម្រួលបទលហុតាមគោលការណ៍ស្ម័គ្រចិត្តរបស់គូភាគី
- ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋ
- ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការពង្រឹងសមត្ថភាពការដោះស្រាយទំនាស់នៅថ្នាក់ភូមិ
- ជួយដល់ក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការរៀបចំ និងបង្កើតក្រុមដោះស្រាយទំនាស់នៅភូមិ



គណៈកម្មាធិការដោះស្រាយទំនាស់ស្ថិតនៅក្នុងសាលាឃុំ សង្កាត់

## ២.១. គោលបំណងនៃក្រមសីលធម៌

ក្រមសីលធមិនេះ ផ្តល់នូវបទដ្ឋាន និងគុណតម្លៃរួមមួយដែលមានគោលបំណង ដើម្បីលើកតម្កើងនូវការអនុវត្តការងារ និងកិត្តិសព្ទរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ហើយនិងសមាជិករបស់ខ្លួន។ ក្រមសីលធមិនេះ រក្សានូវតម្លាភាព ការទទួលខុសត្រូវ និងការគ្រប់គ្រងល្អ ដែលត្រូវប្រតិបត្តិដោយសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ និងអោយយល់បានច្បាស់ទៅលើតួនាទី ភារកិច្ចរបស់ខ្លួន និងមុខងាររបស់គណៈកម្មាធិការ និងការធានានូវគុណភាពនៃការផ្តល់ការសម្រុះសម្រួលដោយសមាជិកគណៈ-កម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់។

## ២.២ ក្រមសីលធម៌នៃវិជ្ជាជីវៈ

### ២.២.១. ការរក្សាភាពសម្ងាត់

គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ គួររក្សានូវភាពសម្ងាត់ឱ្យបានខ្ជាប់ខ្ជួននៅគ្រប់ពេលវេលាទាំងអស់ ហើយចាត់ទុកព័ត៌មានទាំងឡាយ ដែលខ្លួនបានដឹងនៅក្នុងការងាររបស់ខ្លួនជាព័ត៌មានដែលមានបុព្វសិទ្ធិ។ ព័ត៌មានទាំងនោះ មិនគួរត្រូវបានយកទៅអោយដឹងឮទៅដល់ភាគីទី ៣ ដោយគ្មានការអនុញ្ញាតពីភាគីទំនាស់នោះទេ។ កិច្ចការនេះមានសារៈសំខាន់ជាទីបំផុតក្នុងពេលដំណើរការសម្រុះសម្រួល និងក្នុងការរក្សាបាននូវទំនុកចិត្តពីសំណាក់ភាគីចូលរួម។ គ្មានបុគ្គលក្រៅណាម្នាក់ គួរមានវត្តមាននៅក្នុងវគ្គសម្រុះសម្រួលទេ។ ការធ្វើបែបនេះ គឺដើម្បីការពារភាពសម្ងាត់របស់ភាគី និងព្រមទាំងធានាអោយមានសមភាព និងភាពមិនលំអៀងរបស់អ្នកសម្រុះសម្រួលទៅដល់ភាគីទំនាស់។

### ២.២.២. ការរក្សាទុកដាក់ឯកសារ និងការប្រើប្រាស់ព័ត៌មាន

សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ គួរធ្វើការធានាថា ពួកគេរក្សាទុកនូវឯកសារអោយបានត្រឹមត្រូវ និងទាន់សភាពការណ៍ទៅលើទំនាស់នានានៅក្នុងលក្ខណៈមួយ ដូចដែលបានចែងនៅក្នុង "ការសំគាល់សំណុំរឿង ការចុះបញ្ជីសំណុំរឿង ការដាក់លេខរៀងសំណុំរឿងរបស់គណៈកម្មាធិការ" នៅក្នុងសៀវភៅណែនាំនេះ។ ព័ត៌មានទាំងឡាយដែលទាក់ទិនទៅនឹងសំណុំរឿងដែលទទួលបានពីគណៈកម្មាធិការ គួរត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ ហើយមិនគួរត្រូវបានយកទៅប្រើប្រាស់ខាងក្រៅបរិបទវិជ្ជាជីវៈមួយផ្សេងទោះក្នុងរូបភាពណាក៏ដោយ។ ធ្វើរបៀបនេះ គឺដើម្បីរក្សាអោយខ្ជាប់ទៅនឹងការរក្សាភាពសម្ងាត់ដែលទាក់ទិនទៅនឹងសំណុំរឿង ដែលបញ្ជូនមកកាន់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់។

### ២.២.៣. ជំនឿទុកចិត្ត

សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់នានា គួរធ្វើការដើម្បីកសាងនូវជំនឿទុកចិត្តពីសហគមន៍ទាំងឡាយ ដែលពួកគេធ្វើការជាមួយ។ សហគមន៍ដែលពួកគេផ្តល់ការសម្រុះសម្រួលអោយនោះ គួរទទួលបាននូវភាពកក់ក្តៅក្នុងការនាំយកសំណុំរឿងក្តីមក និងស្វែងរកការជួយជ្រោមជ្រែងពីគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់។ បន្ថែមពីលើនេះទៅទៀត ភាពជឿទុកចិត្តក្នុងចំណោមសមាជិកនៅគណៈ-កម្មាធិការ ក៏គួរត្រូវបានធ្វើអោយបានប្រសើរឡើង ដើម្បីរក្សានូវបរិយាកាសធ្វើការងារដ៏ល្អប្រពៃមួយ។

### ២.២.៤. សមធម៌ យុត្តិធម៌ និងសិទ្ធិមនុស្ស

មនុស្សគ្រប់រូប គួរត្រូវទទួលបានសិទ្ធិស្មើៗគ្នា ដោយពុំមានការរើសអើង ការបំពាន និងការកេងប្រវ័ញ្ច។ "យុត្តិធម៌" គឺពាក់ព័ន្ធជាមួយនឹងការបែងចែកអំណាច និងការទប់ស្កាត់នូវការរំលោភអំណាច។ នៅក្នុងសហគមន៍ដែលមានយុត្តិធម៌គ្រប់សមាជិកទាំងអស់ គួរមានលទ្ធភាពទទួលបាននូវឱកាសដែលអនុញ្ញាតិអោយមានការចូលរួមពេញលេញរបស់ពួកគេទៅក្នុងសហគមន៍នោះ។ គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ត្រូវយកចិត្តទៅលើករណីនេះ នៅពេលបំពេញការងាររបស់ខ្លួន។ កេរ្តិ៍ឈ្មោះរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ គឺស្ថិតនៅលើលទ្ធភាពរបស់ខ្លួនក្នុងការលើកកម្ពស់សមធម៌ និងយុត្តិធម៌។ គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ នេះ ត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់ការទទួលបាននូវយុត្តិធម៌នៅឃុំ សង្កាត់។ សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ គួរប្រតិបត្តិនូវការគោរព ការពារ និងលើកតម្កើងអោយមាននូវការបំពេញសិទ្ធិមនុស្ស និងកាតព្វកិច្ចរបស់ប្រទេសកម្ពុជាអោយស្របទៅនឹងច្បាប់ជាតិ និងអន្តរជាតិ។

### ២.២.៥. ការរើសអើង

សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ មិនត្រូវអនុវត្តដោយបណ្តោយអោយមានការជួយសំរួល ឬសហការអោយមានការរើសអើងក្នុងទម្រង់ណាមួយផ្អែកលើសញ្ជាតិ ភេទ អាយុ ស្ថានភាពរៀបការ សាសនា និន្នាការនយោបាយ វិបត្តិផ្លូវចិត្ត ឬបញ្ហាផ្លូវកាយជាដាច់ខាត។

### ២.២.៦. យេនឌ័រ

សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ ត្រូវប្រើប្រាស់ភាសាដែលមិនប៉ះពាល់ទៅដល់ភេទ និងយេនឌ័រនៅក្នុងគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ គ្រប់ពេលទាំងអស់ ជាពិសេស ជាមួយអ្នកដែលមកគណៈកម្មាធិការដោះស្រាយទំនាស់ ឃុំ សង្កាត់ ដើម្បីស្វែងរកសេវា។

គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ជាកន្លែងមួយដែលមានការគោរពគ្នាទៅវិញទៅមករវាងបុគ្គលិកការងារបុរស និងស្ត្រី និងរវាង "ភ្ញៀវ" ជាបុរស និងស្ត្រី ដែលមកកាន់គណៈកម្មាធិការដោះស្រាយទំនាស់។

សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ គួរគោរពភាពសម្ងាត់របស់ភ្ញៀវ ជាពិសេស ទៅលើករណីដែលមានទាក់ទិនទៅនឹងយេនឌ័រ។ (សូមមើលសេចក្តីលំអិតនៅកថាខណ្ឌ "អំពីយេនឌ័រ" ជំពូកទី ៥ នៃសៀវភៅណែនាំនេះ)។

## ២.២.៧. ទំនាស់ផលប្រយោជន៏

សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ គួរចៀសវាងទំនាស់ផលប្រយោជន៏នៅក្នុងពេលបំពេញការងាររបស់ខ្លួន។ ទំនាស់ផលប្រយោជន៏កើតចេញអំពីបុគ្គលណាម្នាក់ដែលដឹងថា ខ្លួនកំពុងត្រូវបានគេបំពាន ហើយបានប៉ះពាល់ដល់ប្រយោជន៏របស់ខ្លួន។ ហេតុដូច្នេះ សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ត្រូវស្គាល់កត្តាដែលមានការពាក់ព័ន្ធគ្នាទាំងនេះ ហើយត្រូវងាកទៅរកការអនុវត្តនីភារកិច្ចរបស់ខ្លួនអោយបានត្រឹមត្រូវនៅក្នុងអាកប្បកិរិយាដែលមិនលម្អៀង។

ឧទាហរណ៏ៈ មាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ មិនគួរធ្វើការសម្រុះសម្រួល និងសំណុំរឿងក្នុងករណី ៈ

- មានភាពលំអៀងទៅលើភាគីណាមួយ ឬក៏បានទទួលព័ត៌មានទាក់ទងនឹងអង្គហេតុ ភស្តុតាងដែលមានជម្លោះទាក់ទិនទៅនឹងដំណើរការសម្រុះសម្រួល
- ជាប់សាច់ញាតិ ( ប្តី ឬប្រពន្ធ បង ឬប្អូន) គូភាគីទំនាស់ណាមួយនៅក្នុងការសម្រុះសម្រួល
- មានផលប្រយោជន៏ដែលអាចប៉ះពាល់លទ្ធផលនៃការសម្រុះសម្រួល

សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ មិនត្រូវមានការរើសអើងដោយការបង្ហាញនូវការពេញចិត្ត ឬផ្តល់សិទ្ធិទៅរកភាគីណាម្នាក់ ទោះជានៅក្នុងកាលៈទេសៈណាក៏ដោយ ហើយមិនទទួលផលប្រយោជន៏ដោយមានការយកចិត្តទុកដាក់ជាពិសេសពីជនណាម្នាក់ ដែលនាំឱ្យមានការជះឥទ្ធិពលទៅលើការបំពេញតួនាទីរបស់ខ្លួន។

***កំណត់ចំណាំៈ***

*ដើម្បីធានានូវសេវាកម្មល្អផ្តល់ជូនប្រជាពលរដ្ឋគ្រប់ក៏រិត និងឆ្លើយតបទៅនឹងតម្រូវការគម្រោងសិទ្ធិទទួលបានយុត្តិធម៌មានដាក់ប្រអប់គណនេយ្យភាពមួយ នៅតាមមាត់ផ្លូវចូលនៅមណ្ឌលសេវាកម្មយុត្តិធម៌នីមួយៗ ដើម្បីប្រជាពលរដ្ឋដែលទទួលបាននូវសេវាកម្មនេះ អាចសរសេរនូវសំនួរ ឬសរសេរអំពីសំណើផ្សេងៗ ឬការរិះគន់ផ្សេងៗទៅលើការងាររបស់មណ្ឌលសេវាកម្មយុត្តិធម៌ (ឬគណៈកម្មាធិការដោះស្រាយទំនាស់)។ មន្ត្រីមណ្ឌលសេវាកម្មយុត្តិធម៌ ពុំមានសិទ្ធិដើម្បីបើកប្រអប់នេះទេ គឺមានតែមន្ត្រីរបស់គម្រោងថ្នាក់ជាតិរបស់ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃទេ ដែលមានសិទ្ធិបើកប្រអប់នេះនឹងប្រមូលសំនួរ សំណូរពរ យោបល់ ឬមតិរិះគន់កែលំអការងាររបស់មណ្ឌលសេវាកម្មយុត្តិធម៌។*

# ៣ នីតិវិធីនៃការសម្រុះសម្រួល

## ៣.១. នីតិវិធីនៃការសម្រុះសម្រួល

### ៣.១.១. ការទទួលពាក្យបណ្តឹង

- ពាក្យបណ្តឹងអាចធ្វើឡើងជាលាយលក្ខណ៍អក្សរនៅគណៈកម្មាធិការដោះស្រាយទំនាស់ ដែលស្ថិតនៅក្នុងសាលាឃុំ សង្កាត់។ ពាក្យបណ្តឹងអាចធ្វើឡើងដោយផ្ទាល់មាត់ ប្រសិនបើដើមបណ្តឹងមិនចេះអក្សរ។ ក្នុងករណីនេះ អ្នកទទួលពាក្យបណ្តឹងត្រូវជួយបំពេញពាក្យបណ្តឹងអោយដើមបណ្តឹង និងអានអោយភាគីស្តាប់។ (សូមមើលនៅក្នុងជំពូក ៧.២)
- ពាក្យបណ្តឹងទាំងអស់ ត្រូវផ្តិតស្នាមមេដៃ និងចុះនៅក្នុងបញ្ជីទទួលពាក្យបណ្តឹង។ (សូមមើលនៅក្នុងជំពូក ៧.១)
- សមាជិកគណៈកម្មាធិការដែលទទួលពាក្យបណ្តឹងត្រូវចេញបង្កាន់ដៃទទួលពាក្យបណ្តឹង អោយដើមបណ្តឹង និងប្រាប់ពីសិទ្ធិក្នុងការជ្រើសរើសអ្នកសម្រុះសម្រួល។ (សូមមើលនៅក្នុងជំពូក ៧.៣)
- សមាជិកគណៈកម្មាធិការដែលទទួលពាក្យបណ្តឹងត្រូវបញ្ជូនពាក្យបណ្តឹងទៅប្រធានគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ក្នុងរយៈពេល ១ ថ្ងៃ (ថ្ងៃធ្វើការ) យ៉ាងយូរ ចាប់ពីថ្ងៃទទួលពាក្យ។
- ប្រធានគណៈកម្មាធិការដោះស្រាយទំនាស់ ត្រូវធ្វើលិខិតជូនដំណឹងទៅដល់ចុងចម្លើយក្នុងរយៈពេល ២ ថ្ងៃ យ៉ាងយូរ ដោយបង្ហាញប្រាប់អំពីឈ្មោះដើមបណ្តឹង កម្មវត្ថុនៃពាក្យបណ្តឹង និងសិទ្ធិក្នុងការជ្រើសរើសអ្នកសម្រុះសម្រួល។ (សូមមើលនៅក្នុងជំពូក ៧.២)

### ៣.១.២. សិទ្ធិក្នុងការជ្រើសរើសអ្នកសម្រុះសម្រួលដោយគូភាគី

- ដើមបណ្តឹងមានសិទ្ធិជ្រើសរើសអ្នកសម្រុះសម្រួលម្នាក់ដែលខ្លួនទុកចិត្ត។
- ចុងចម្លើយមានសិទ្ធិជ្រើសរើសអ្នកសម្រុះសម្រួលម្នាក់ដែលខ្លួនទុកចិត្ត។
- អ្នកសម្រុះសម្រួលទាំងពីរនាក់ដែលបានភាគីទំនាស់ជ្រើសរួចហើយ ត្រូវជ្រើសរើសសមាជិកមួយរូបផ្សេងទៀតពីគណៈកម្មាធិការដោះស្រាយទំនាស់ក្នុងរយៈពេល ២ ថ្ងៃ មុនដំណើរការសម្រុះសម្រួលចាប់ផ្តើម ដើម្បីអោយជួយធ្វើជាអ្នកកត់ត្រានូវកំណត់ហេតុ។

- ក្នុងករណីដែលភាគីទាំងពីរជ្រើសរើសយកអ្នកសម្រុះសម្រួលតែម្នាក់ អ្នកសម្រុះសម្រួលនោះត្រូវជ្រើសរើសសមាជិកម្នាក់ទៀត មកពីគណៈកម្មាធិការដោះស្រាយទំនាស់ក្នុងរយៈពេល ២ ថ្ងៃមុនដំណើរការសម្រុះសម្រួលចាប់ផ្តើម ដើម្បីអោយជួយធ្វើជាអ្នកកត់ត្រានូវកំណត់ហេតុ។

### ៣.១.៣. ការកំណត់កាលបរិច្ឆេទ និងទីកន្លែងដើម្បីធ្វើការសម្រុះសម្រួល

- គណៈកម្មាធិការដោះស្រាយទំនាស់ស្ថិតនៅក្នុងសាលាឃុំ ឬសាលាសង្កាត់
- គណៈកម្មាធិការដោះស្រាយទំនាស់ ត្រូវជូនដំណឹងដល់គូភាគីអំពីថ្ងៃសម្រុះសម្រួលអោយបានយ៉ាងតិច ៣ ថ្ងៃ មុនកាលបរិច្ឆេទនៃការសម្រុះសម្រួល។
- គណៈកម្មាធិការដោះស្រាយទំនាស់ ត្រូវអញ្ជើញគូភាគីមកធ្វើការសម្រុះសម្រួលក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរ ក្រោយពីគូភាគីបានជ្រើសរើសអ្នកសម្រុះសម្រួលហើយ។

*កំណត់ចំណាំ:*

*នៅក្នុងបន្ទប់របស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ មានដាក់តាំងរូបថតរចនាសម្ព័ន្ធនៃសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ទាំង ៧ រូប ដោយព្យួរភ្ជាប់ទៅនឹងជញ្ជាំងនៅក្នុងបន្ទប់សម្រុះសម្រួលនោះ។ ភាគីទំនាស់អាចជ្រើសរើសអ្នកសម្រុះសម្រួលម្នាក់ដែលខ្លួនស្គាល់តាមរយៈរូបថតទាំងនោះ ឬសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ អាចណែនាំភាគីទំនាស់អោយជ្រើសរើសអ្នកសម្រុះសម្រួលម្នាក់ដោយផ្ទាល់តែម្តង បើអ្នកសម្រុះសម្រួលមានវត្តមាននៅទីនោះ។*

## ៣.២. ដ្យាក្រាមនីតិវិធីសម្រុះសម្រួលនៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់



## ៣.៣. ការសម្រុះសម្រួលលើកទី ១

ផ្នែកនេះពន្យល់ដោយសង្ខេបអំពីជំហាននានា ដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលនៃការសម្រុះសម្រួលលើកទី ១ :

*« សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ត្រូវជួបជាមួយភាគីទំនាស់នីមួយៗ ដាច់ដោយឡែកពីគ្នា ដើម្បីស្វែងយល់អំពីទំនាស់ អង្គហេតុនៃទំនាស់ និងអារម្មណ៍របស់ភាគីនីមួយៗ ហើយដើម្បីបញ្ជាក់ថា ភាគីទំនាស់ពិតជាត្រូវការសេវាកម្មសម្រុះសម្រួល ។ ទោះជាយ៉ាងណាក្តី នេះពុំមែនជាជំហានចាំបាច់នោះទេ ។ »*

១. **ភ្ញៀវមកកាន់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់**

២. **ស្វាគមន៍ពួកគេឱ្យចូលទៅក្នុងបន្ទប់សម្រុះសម្រួល**

កិច្ចស្វាគមន៍នេះ គួរនិយាយថា :

*« ... សូមកោតសរសើរអ្នកដែលបានអញ្ជើញមកទីនេះ ដែលបង្ហាញថា អ្នកខំប្រឹងប្រែងរកដំណោះស្រាយទំនាស់របស់អ្នក ។ »*

៣. **ធ្វើការណែនាំខ្លួនអ្នក និងតួនាទីរបស់អ្នក**

*« ខ្ញុំឈ្មោះ......... តួនាទីរបស់ខ្ញុំនៅទីនេះ ជាសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ដែលមានភារកិច្ចជួយអ្នក ដើម្បីរកដំណោះស្រាយទំនាស់របស់អ្នកតាមរយៈការសម្រុះសម្រួល ។ »*

៤. **ជំរាបប្រាប់ភាគីទំនាស់អំពីពេលវេលារបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ហើយសួរទៅភាគី តើគេមានពេលវេលាប៉ុន្មានសម្រាប់ធ្វើការងារនេះ**

*« ពេលវេលាសម្រាប់ធ្វើការសម្រុះសម្រួលអាចមានភាពប្រែប្រួល អាស្រ័យលើរឿងរ៉ាវនៃទំនាស់ និងឆន្ទៈរបស់ភាគីទំនាស់ដែលត្រូវបន្ត ។ គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ គួរប្រើពេលវេលាយ៉ាងតិចកន្លះថ្ងៃ ឬអាចយូរជាងនេះ ប្រសិនបើចាំបាច់ក្នុងការសម្រុះសម្រួលម្តង ។ ប៉ុន្តែប្រសិនបើភាគី ទំនាស់មានឆន្ទៈចង់បន្តការសម្រុះសម្រួលធ្វើទៅតាមនោះ ។ ទោះជាយ៉ាងណាក្តី គណៈកម្មាធិការ គួរខិតខំធ្វើយ៉ាងណាដើម្បីអោយភាគីទំនាស់ចរចាគ្នាដើម្បីដោះស្រាយទំនាស់របស់ពួកគេ ។ »*

៥. សាកសួរពួកគេថា តើពួកគេដឹងអំពីគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ តាមរបៀបណា

## ៦. ពន្យល់ពួកគេដោយសង្ខេប និងយ៉ាងសាមញ្ញអំពីភារកិច្ច និងប្រវត្តិសង្ខេបអំពីគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

ព័ត៌មានខ្លីដែលត្រូវជំរាបទៅភាគីវិវាទ ដោយសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ៖

*« គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ត្រូវបានបង្កើតឡើងដោយក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីជួយប្រជាជនដែលរស់នៅក្នុងតំបន់ជនបទដាច់ស្រយាល អោយទទួលបានយោបល់ ដំបូន្មាន និងការជួយជ្រោមជ្រែងទៅលើបញ្ហា និងវិវាទដែលពួកគេកំពុងជួបប្រទះ ។ ប្រសិនបើប្រជាជនចង់ប្រើសេវាកម្មរបស់យើង គណៈកម្មាធិការអាចធ្វើជាអ្នកសម្រុះសម្រួល និងស្តាប់ភាគីជម្លោះទាំងឡាយ ដើម្បីព្យាយាម និងជួយក្នុងការដោះស្រាយទំនាស់របស់ពួកគេ ។ តាមពិតទៅ នេះ គឺជាដំណើរការស្ម័គ្រចិត្តទាំងស្រុង ។ យើងមិនអាចបង្ខំការសម្រេចណាមួយលើលោកអ្នកបានទេ ហើយយើងនឹងស្នើទៅកាន់លោកអ្នកអំពីវិធីដោះស្រាយទំនាស់របស់លោកអ្នក ។ យើងក៏អាចផ្តល់ជាគំនិតយោបល់ផ្នែកច្បាប់ផងដែរ ប្រសិនបើលោកអ្នកមានបំណងយកទំនាស់របស់លោកអ្នកទៅកាន់តុលាការ ។ »*

## ៧. ពន្យល់ដោយសង្ខេបពីដំណើរការនៃការសម្រុះសម្រួល

### *អ្វីទៅជាការសម្រុះសម្រួល?*

ការសម្រុះសម្រួលជាដំណើរការមួយ ដែលជួយភាគីអោយធ្វើការប្រាស្រ័យទាក់ទងគ្នា និងចរចារកដំណោះស្រាយចំពោះទំនាស់របស់ពួកគេ ។ តួនាទីរបស់ខ្ញុំ (យើងខ្ញុំ) គឺជួយស្វែងយល់ថា តើអាចមានច្រកចេញណា ដើម្បីអោយអ្នកឈានទៅដល់ការដោះស្រាយមួយដែលមានការឯកភាពទាំងសងខាង ។ ខ្ញុំអាចនឹងជួយអ្នកតាមវិធីខុសៗគ្នាជាច្រើន ។ តែខ្ញុំចង់បញ្ជាក់អោយបានច្បាស់ពីដំបូងអោយហើយថា ខ្ញុំអាចត្រឹមតែជួយអោយលោក អ្នកធ្វើការចរចា និងប្រាស្រ័យទាក់ទងជាមួយគ្នាតែប៉ុណ្ណោះ គឺថា ខ្ញុំមិនមែនជាចៅក្រមទេ ហើយក៏ពុំមានអំណាចអ្វី ដើម្បីសម្រេចលើរឿងក្តីនេះដែរ ។ អាចសម្រេចចិត្តបានគ្រប់ពេលថា តើអ្នកចង់បន្តជាមួយដំណើរការនេះ ឬមួយដើរចេញ ទោះបីជាខ្ញុំអាចផ្តល់ជាដំបូន្មាន ក៏ដូចជាការប្រមើលមើលខ្លះអំពីថា តើការចរចាទំនងជាឈានទៅកាន់ផ្លូវណាក៏ដោយ ។



ផ្តល់ព័ត៌មានទូទៅ និង ដំបូន្មានផ្នែកច្បាប់

ចំណុចសំខាន់មួយក្នុងចំណោមចំណុចសំខាន់ដ៏ច្រើននៃដំណើរការនេះ ឋិតនៅត្រង់ថា វាមានលក្ខណៈរក្សាការសម្ងាត់។ អ្នកទាំងអស់គ្នាបានចុះហត្ថលេខារួចរាល់ហើយ លើកិច្ចព្រមព្រៀងសម្រុះសម្រួលដោយកិច្ចព្រមព្រៀង នោះមានខបញ្ញត្តិមួយ ដែលហាមមិនអោយភាគីណាមួយបើកកកាយពីអ្វី ដែលបាននិយាយនៅក្នុងការសម្រុះសម្រួលនោះឡើយ។ មានតែភាគីនៅទីនោះទេ ដែលនឹងក្លាយជាភាគីពាក់ព័ន្ធ ហើយពុំមានអ្នកក្រៅណាមកចូលរួមនៅក្នុងដំណើរការនេះទេ។ បើជម្លោះមិនអាចដោះស្រាយបាន ខ្ញុំលែងមានតួនាទីទៀតនៅក្នុងដំណើរការនេះ ហើយប្រសិនបើមានភាគីណាម្ខាងនឹងបន្តប្តឹងទៅតុលាការ ព័ត៌មានអ្វីដែលបាននិយាយនៅក្នុងដំណើរការសម្រុះសម្រួលនេះ នឹងមិនត្រូវបានរាយការណ៍ទៅកាន់ចៅក្រមជាដាច់ខាត។

ត្រូវតែធ្វើឱ្យបានច្បាស់លាស់នូវអ្វីដែលបានពន្យល់បង្ហាញជូនដល់ភាគីវិវាទនោះថា ការសម្រុះសម្រួលគឺជាដំណើរការដោយស្ម័គ្រចិត្តសុទ្ធសាធ និងពុំមានភ្ជាប់កាតព្វកិច្ច។

ការសម្រុះសម្រួលមិនដូចគ្នានឹងនីតិវិធីក្នុងតុលាការទេ គឺមិនមានមេធាវីតំណាងភាគីទំនាស់ចូលមកក្នុងការសម្រុះសម្រួលទេ។ ដោយឈរលើភាពមិនលម្អៀង និងការសម្ងាត់ មានតែភាគីទំនាស់ និងអ្នកសម្រុះសម្រួលដែលជាសមាជិករបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ប៉ុណ្ណោះ ដែលមានវត្តមាននៅក្នុងដំណើរការសម្រុះសម្រួល។

**៨. សាកសួរភាគីវិវាទទាំងសងខាងនោះ ដើម្បីផ្តល់នូវសេចក្តីសង្ខេបមួយ អំពីមូលហេតុដែលពួកគេមកកាន់គណៈកម្មាធិការ (ដោយការកំណត់ ៥ នាទី សម្រាប់ភាគីទំនាស់នីមួយៗ)។ កត់ត្រានូវករណីទំនាស់របស់ពួកគេនៅក្នុងសៀវភៅកំណត់ត្រា។**

**៩. សូមកំណត់ឱ្យច្បាស់ តើប្រភេទសំណុំរឿងវិវាទនោះ អាចធ្វើការសម្រុះសម្រួលបានទេ (សូមមើលនៅកថាខណ្ឌ ៧.៥ "សំណុំរឿងដែលអាចធ្វើការសម្រុះសម្រួល និងសំណុំរឿងដែលមានលក្ខណៈរសើប" ដែលអាច និងមិនអាចធ្វើការសម្រុះសម្រួលបាន)។ សូមធ្វើការកត់ចំណាំក្នុងចិត្តថា ការសម្រុះសម្រួលអាចដំណើរការទៅបានល្អបំផុត តែក្នុងចំណោមភាគីដែលនៅមានការប្រាស្រ័យទាក់ទងនឹងគ្នានៅឡើយ។**

សាកសួរពួកគេថា តើចង់ចូលរួមក្នុងដំណើរការសម្រុះសម្រួលជាមួយគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ដែរឬទេ ដើម្បីព្យាយាមដោះស្រាយទំនាស់។ សូមធ្វើឱ្យប្រាកដថា ភាគីចុងចម្លើយបានចុះហត្ថលេខាព្រមព្រៀង យល់ព្រមទទួលយកសេវាកម្មសម្រុះសម្រួលនេះ (សូមមើលនៅកថាខណ្ឌ ៧.៥)។

១០. ជម្រាបជូនដល់ពួកគេអំពីការអនុវត្តន៍នូវបទបញ្ជាផ្ទៃក្នុង និងការទទួលខុសត្រូវក្នុងពេលធ្វើការសម្រុះសម្រួល

- កុំនិយាយកាត់គ្នាពេលដែលភាគីម្ខាងទៀតកំពុងនិយាយ ។ អ្នកនឹងមានឱកាសដើម្បីនិយាយម្តងម្នាក់ ។
- សូមស្តាប់ដោយយកចិត្តទុកដាក់នូវអ្វីដែលភាគីម្ខាងទៀតកំពុងនិយាយ ។
- មិនត្រូវអោយមានការបំភិតបំភ័យ ឬបំពារបំពានដោយប្រការណាមួយឡើយទាំងលើផ្នែករាងកាយ និងពាក្យសម្តី ។
- សូមបង្ហាញនូវភាពស្មោះត្រង់អោយអស់លទ្ធភាព ។
- អ្វីទាំងអស់ដែលនិយាយចេញមកនឹងត្រូវរក្សាជាការសម្ងាត់ ។
- អ្នកមានសេរីភាពក្នុងការដើរចេញគ្រប់ពេល ពោល គឺយើងមិនអាចបង្ខំអ្នកឱ្យធ្វើការសម្រុះសម្រួលឡើយ ។

១១. ពន្យល់ពួកគេអំពីរបៀបវារៈនៃការសម្រុះសម្រួល (ឧទាហរណ៍ : ១ ម៉ោង សម្រាប់ភាគីនិយាយអំពីរឿងទំនាស់របស់ខ្លួន-សំរាក-១ ម៉ោងទៀត សម្រាប់ការពិភាក្សា សេចក្តីថ្លែងការណ៍សម្រុះសម្រួល សេចក្តីសន្និដ្ឋាន ការសម្រេចចិត្តថា តើនឹងត្រូវមានការសម្រុះសម្រួលលើកក្រោយទៀត ឬយ៉ាងណា)

« *ប្រសិនបើចាំបាច់ ត្រូវអនុញ្ញាតអោយភាគីទំនាស់ដកឃ្លាមួយរយៈសិន ដើម្បីអោយពួកគេត្រជាក់ចិត្ត បន្ទាប់មក អោយពួកគេចូលមកវិញ ។* »

១២. ការប្រជុំរួម - នេះជាពេលដែលភាគីទាំងសងខាងនៃជម្លោះ មានឱកាសបង្ហាញពីបញ្ហាចេញពីទស្សនៈរបស់ខ្លួន*ដោយពុំមានការរំខាន*។ មានតែអ្នកសម្រុះសម្រួលទេដែលអាចសួរសំណួរ ឬសង្ខេបឡើងវិញពីអ្វីដែលពួកគេបាននិយាយ។ សំណួររបស់អ្នកសម្រុះសម្រួល គួរតែសួរឡើងក្នុងន័យដើម្បីបញ្ជាក់អោយបានច្បាស់ពីមតិយោបល់របស់ភាគីទាំងពីរដោយការប្រើសំណួរបើក និងអោយភាគីបង្ហាញអំពីសេចក្តីសង្ឃឹមរបស់ពួកគេ ការរំពឹងទុក អារម្មណ៍ និងគំនិត ឬដំណោះស្រាយ។

*ការប្រជុំសម្ងាត់ជាជាមួយភាគីម្នាក់ម្តងជាឯកជន* - ក្រោយការប្រជុំរួមចប់ អ្នកអាចប្រជុំជាលក្ខណៈដាច់ដោយឡែកជាមួយភាគីនីមួយរៀង២ខ្លួន ដើម្បីបញ្ជាក់អោយបានកាន់តែច្បាស់ថែមទៀតអំពីបញ្ហា និងជំហរ ។ អ្នកសម្រុះសម្រួលនឹងមិនបង្ហាញព័ត៌មានដែលបានពីការប្រជុំសម្ងាត់នោះទៅភាគីម្ខាងទៀត ដោយពុំមានការអនុញ្ញាតឡើយ ។

**១៣. ការពិភាក្សា : នៅក្នុងពេលសម្រុះស្រួល អ្នកសម្រុះសម្រួលត្រូវកំណត់អំពីបញ្ហាអោយបានច្បាស់ និងកំណត់អំពីដំណោះស្រាយដែលលើកឡើងដោយភាគីទំនាស់។ អ្នកសម្រុះសម្រួលត្រូវទទួលយកនូវជម្រើសផ្សេងៗរបស់ភាគីទំនាស់នឹងអារម្មណ៍របស់ពួកគេទៅនឹងជម្រើសទាំងនេះ។**

ទោះជាដំណើរការសម្រុះសម្រួលកំណត់បានច្បាស់នូវបញ្ហា និងជម្រើសយ៉ាងណាក៏ដោយភាគីទំនាស់អាចសម្តែងទឹកចិត្ត ឬអារម្មណ៍របស់ខ្លួនអំពីបញ្ហានេះ ។ ប្រសិនបើបានស្តាប់អំពីអារម្មណ៍របស់ភាគីទំនាស់ដែលបានសម្តែងចេញមកនោះ នាំអោយភាគីអាចធ្វើការឆ្ពោះទៅរកដំណោះស្រាយបាន ។ សូមផ្តល់ពេលវេលាសម្រាប់ភាគីសម្តែងអំពីអារម្មណ៍របស់គេ ដែលពុំមែនជាអង្គហេតុនៃរឿងទំនាស់ប៉ុណ្ណោះទេ ។

នៅក្នុងដំណើរការសម្រុះសម្រួលនេះ អ្នកសម្រុះសម្រួលត្រូវព្យាយាមជួយភាគីជម្លោះឱ្យដោះស្រាយទំនាស់បានប្រកបដោយលក្ខណៈភាតរភាព ឬអធ្យាស្រ័យល្អ អ្នកសម្រុះសម្រួលអាចនឹងអនុវត្តតាមវិធីណាមួយដូចខាងក្រោមនេះ[9] :

- ជួយកាត់បន្ថយភាពប្រទូសរ៉ាយ និងភាពតានតឹងរវាងភាគីជម្លោះ ហើយលើកទឹកចិត្តអោយមានសហប្រតិបត្តិការល្អ
- ជួយភាគីជម្លោះអោយយកចិត្តទុកដាក់ទៅលើបញ្ហាដែលចាំបាច់ដល់ការដោះស្រាយទំនាស់បាន
- ទំនាក់ទំនងអោយភាគីជម្លោះ ប្រសិនបើពួកគេមិនអាចនិយាយរកគ្នាដោយផ្ទាល់ទេ
- ជួយភាគីជម្លោះនីមួយៗអោយបញ្ជាក់ និងពន្យល់ពីចំណាប់អារម្មណ៍របស់ភាគីរៀងៗខ្លួន
- ជួយភាគីជម្លោះប្តូរពី "ជំហរ" ដែលកំណត់ទុកជាមុន បែរទៅរកជម្រើសផ្សេងៗ ដែលមានលក្ខណៈប្រាកដប្រជា និងមិនលំអៀងវិញ
- ជួយភាគីជម្លោះអោយបង្កើត និងវិភាគជម្រើសផ្សេងៗនៃដំណោះស្រាយ
- ជួយភាគីជម្លោះអោយដាក់ដំណោះស្រាយរបស់ខ្លួនទៅក្នុងកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ និង
- ជួយពិនិត្យទៅលើការបំពេញលើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរនោះ ។

**១៤. សេចក្តីសន្និដ្ឋាន : ចុងបញ្ចប់នៃការសម្រុះសម្រួល អ្នកសម្រុះសម្រួលត្រូវរំលឹកឡើងវិញដោយខ្លីៗអំពីជម្រើសផ្សេងៗដែលបានពិភាក្សា។ ប្រសិនបើឈានដល់ការព្រមព្រៀងគ្នា គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ រួមជាមួយភាគីទំនាស់នឹងសរសេរអំពីការព្រមព្រៀងនេះ ដែលនឹងត្រូវចុះហត្ថលេខា ឬផ្តិតមេដៃនៅលើការព្រមព្រៀងនេះផងដែរ។**

*" ព្យាយាមតាមដានមើលថា តើភាគីទំនាស់គោរពតាមកិច្ចព្រមព្រៀងដែរឬទេ ។ ប្រសិនមើលឃើញថា ជាការចាំបាច់ អាចស្នើដល់ពួកគេដើម្បីចូលមកកាន់នីតិវិធីសម្រុះសម្រួលជាថ្មីម្តងទៀត ។ "*

---

[9] *King and Rendall, "ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ" CLEC, ទំព័រ ១០៨*




*កិច្ចព្រមព្រៀងកើតចេញពីភាគីជាអ្នកសម្រេច*

១៥. ប្រសិនបើភាគីមិនអាចឈានដល់ការព្រមព្រៀងគ្នាទេ អ្នកអាចស្នើពួកគេថា តើពួកគេចង់បន្តដំណើរការសម្រុះសម្រួលទៀតដែរឬទេ។ ប្រសិនបើពួកគេមិនត្រូវការទៀតទេ ឬមួយពួកគេមិនបង្ហាញមុខនៅក្នុងពេលសម្រុះសម្រួលទេ សំណុំរឿងវិវាទនេះត្រូវបញ្ចប់ដោយពុំទទួលបានជោគជ័យទេ។

*" សូមកត់ចំណាំថាការសម្រុះសម្រួល អាចប្រព្រឹត្តទៅរហូតដល់ពារលើក ។ សូមអោយភាគីទំនាស់មានភាពអត់ធ្មត់ ហើយអោយពួកគេត្រឡប់ទៅផ្ទះវិញ ដើម្បីគិតគូរអំពីបញ្ហានេះ និងប្រមើលមើលនូវជម្រើសផ្សេងៗ ដែលត្រូវលើកយកមកពិភាក្សាគ្នាជាបន្តទៀត ។*

*ព័ត៌មាន និងគោលការណ៍បន្ថែមអំពីការសម្រុះសម្រួល សូមមើលទៅជំពូក ៦ ស្តីអំពី "គោលការណ៍ និងបច្ចេកទេសនៃការសម្រុះសម្រួល" ។ "*

# ៤ ការគ្រប់គ្រងសំណុំរឿង នៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

## ៤.១. ការសំគាល់ ការចុះបញ្ជី ការដាក់លេខរៀងសំណុំរឿង នៅគណៈកម្មាធិការដោះស្រាយ ទំនាស់ឃុំ សង្កាត់

ទោះបីជាគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ មិនមែនជាស្ថាប័នច្បាប់ ឬមណ្ឌលសេវាកម្មយុត្តិធមិក៏ដោយ គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ គួរថែក្សាទុវសំណុំឯកសារការងារដែលស្រដៀងទៅនឹងរបៀបដែលមណ្ឌលសេវាកម្មយុត្តិធមិ និងតុលាការបានធ្វើដែរ ក្នុងការបង្កើតប្រព័ន្ធតាមដានសំណុំរឿងដែលមានលក្ខណៈងាយស្រួលក្នុងការប្រើប្រាស់ឱ្យមានភាពត្រឹមត្រូវ និងទាន់ទៅតាមសម័យកាល ។ សំណុំរឿងដែលបានបញ្ជូនមកកាន់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ គួរត្រូវបានរក្សាទុកដោយមានភាពសម្ងាត់តឹងរ៉ឹង ហើយសំណុំរឿងគួរត្រូវបានចាក់សោរជាប្រចាំនៅពេលចប់ការងារនាថ្ងៃនីមួយៗ ។

ការរក្សាទុកសំណុំឯកសារនានាដោយមានរបៀបរៀបរយ និងលំដាប់លំដោយត្រឹមត្រូវនៅក្នុងការិយាល័យ គឺមានសារៈសំខាន់ក្នុងការរក្សានូវភាពត្រឹមត្រូវនៃការងាររបស់គណៈកម្មាធិការដោះស្រាយទំនាស់ ។ បើពុំមានព័ត៌មានត្រឹមត្រូវ និងបើកចំហរនោះទេ វាពុំមានវិធីណាមួយ ដើម្បីស្វែងយល់អំពីការងាររបស់គណៈកម្មាធិការ និងធ្វើការវាយតម្លៃថា តើការងាររបស់គណៈកម្មាធិការដោះស្រាយទំនាស់ឆ្លើយតបទៅនឹងគោលបំណង មុខងារ និងសេចក្តីត្រូវការរបស់សហគមន៍ដែលបានចែងឡើងឡើយ ។ គ្រប់សកម្មភាព និងសេចក្តីសម្រេចទាំងអស់ គួរត្រូវបានកត់ត្រាទុកនៅក្នុងឯកសាររបស់គណៈកម្មាធិការដោះស្រាយទំនាស់ សម្រាប់ជាឯកសារយោងតាមការចាំបាច់ ហើយធ្វើការពិនិត្យឡើងវិញទៅលើគម្រោង ។ ប្រព័ន្ធកត់ត្រារបស់គណៈកម្មាធិការ គួររៀបចំអោយមានសំណុំរឿងនៃគ្រប់បណ្តឹងនៃការសម្រុះសម្រួលទាំងអស់ ដែលបង្កលក្ខណៈងាយស្រួលនៅពេលដែលយើងត្រូវការមានព័ត៌មានទាំងនោះ ។



ការខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ត្រូវតែធ្វើឡើងដើម្បីធានាថា ការងាររបស់ខ្លួន គឺមានតម្លាភាព និងមានតម្លៃទៅលើភាពទំនុកចិត្តរបស់សហគមន៍ ។ លើសពីនេះទៅទៀត គម្រោងសិទ្ធិទទួលបានយុត្តិធមិ នឹងត្រូវបានតាមពិនិត្យ និងវាយតម្លៃយ៉ាងជាប់លាប់ ហើយឯកសារទាំងអស់ ដែលរក្សាទុកនឹងត្រូវធ្វើការពិនិត្យឡើងវិញនៅក្នុងដំណើរការនេះ ។

ជំហានខាងក្រោមនេះ គួរត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្ន និងស្របគ្នានៅតាមគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ដូចខាងក្រោម :

១. ការសំគាល់សំណុំរឿង

២. ការចុះបញ្ជីសំណុំរឿង

៣. ការដាក់លេខរៀងសំណុំរឿង

៤. ការបង្កើតប្រអប់សំណុំរឿង

៥. ការរៀបចំអោយបានត្រឹមត្រូវ ទៅលើប្រអប់សំណុំរឿងនៅក្នុងកន្លែងកំណត់

## ៤.១.១. ការសំគាល់សំណុំរឿង

នៅពេលភាគីទំនាស់មួយនាំយករឿងវិវាទមកកាន់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ការងារទីមួយដែលសមាជិកគណៈកម្មាធិការ គួរធ្វើបន្ទាប់ពីបានស្តាប់នូវពាក្យបណ្តឹង គឺកំណត់នូវប្រភេទបណ្តឹង ដូច្នេះសមាជិកគណៈកម្មាធិការអាចបង្កើតនូវប្រអប់ "ភ្ញៀវ" ថ្មីមួយ ។

តាមការសង្កេតជាសង្ខេបមួយទៅលើសំណុំរឿង ដែលទទួលបានដោយគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ នាពេលកន្លងមក ទំនាស់ភាគច្រើនត្រូវបានចាត់ចូលទៅក្នុងប្រភេទ ដូចតទៅ :

- ទំនាស់អំពីដីធ្លី
- ទំនាស់អំពីការជំពាក់ប្រាក់ និងកិច្ចសន្យា
- ទំនាស់រវាងប្តី ឬប្រពន្ធ
- ទំនាស់អំពីបរិហារកេរ្តិ៍ ឬជេរប្រមាថ
- ទំនាស់អំពីផ្តាច់ពាក្យរៀបការ
- ទំនាស់ទ្រព្យសម្បត្តិ
- ការផ្សះផ្សាលើការលែងលះ ( ដោយមកពីអំពើហិង្សាក្នុងគ្រួសារ)
- បញ្ហាផ្សេងៗក្នុងគ្រួសារ
- ទំនាស់បង្កការខូចខាតទ្រព្យសម្បត្តិតូចតាច
- ការបង្ករបួសស្នាមតូចតាច
- ករណីផ្សេងៗទៀត

វាប្រហែលជាមានសំណុំរឿងផ្សេងទៀត ដែលនឹងត្រូវបន្ថែមនៅពេលដែលគណៈកម្មាធិការទទួលបាននូវសំណុំរឿងវិវាទច្រើនថែមទៀត ហើយប្រភេទរឿងថ្មីៗ អាចនឹងត្រូវបានបង្កើតឡើង ឬក៏អាចដាក់បញ្ចូលទៅក្នុងប្រភេទ "ផ្សេងៗ" ។

វាអាចមានករណីខ្លះទៀត ដែលសំណុំរឿងអាចមានច្រើនជាងមួយប្រភេទ ដូចជា "វិវាទដីធ្លី" និង "ទំនាស់បញ្ហាគ្រួសារ" ឧទាហរណ៍ ភាគីជាសមាជិកគ្រួសារមានជម្លោះពីដីធ្លី។ ក្នុងករណីរបៀបនេះ សំណុំរឿងនោះ គួរត្រូវបានដាក់នៅក្រោមចំណងជើងទាំងពីរ ជាសំណុំរឿងវិវាទដីធ្លី និងវិវាទបញ្ហាគ្រួសារ។

## ៤.១.២. ការចុះបញ្ជីសំណុំរឿង

ការចុះបញ្ជីសំណុំរឿង ដែលបានបញ្ជូនមកកាន់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ គួរកត់ត្រាចូលទៅក្នុងសៀវភៅចុះបញ្ជីតាមលេខរៀងលំដាប់លំដោយ នៃសំណុំរឿងរបស់គណៈកម្មាធិការដោះស្រាយទំនាស់។ សំណុំរឿងរបស់គណៈកម្មាធិការនឹងត្រូវបានកត់ត្រាទុកដោយប្រើប្រាស់ព័ត៌មានដូចតទៅ : លេខយោងសំណុំរឿង ថ្ងៃខែឆ្នាំ ចុះសំណុំរឿង (ថ្ងៃខែឆ្នាំ) ឈ្មោះរបស់ភាគី (ឧ. យិន ប៊ុនលី/មុន សុភាព) ភេទរបស់ចុងចម្លើយ (ឬប្រសិនបើសំណុំរឿងនេះទាក់ទិនទៅនឹងបញ្ហាយេនឌ័រ បើទោះបីជាបុរសជាអ្នកដាក់ពាក្យប្ដឹងសំណុំរឿងនោះក៏ដោយ) ប្រធានបទរបស់សំណុំរឿង (រឿងដីធ្លី)។

ដោយសារតែវាជាការសំខាន់ក្នុងការបែងចែកសំណុំរឿង ដែលប្ដឹងដោយស្ត្រី និងបុរស ដូចនេះសំណុំរឿងណាដែលប្ដឹងដោយស្ត្រីនឹងចាប់ផ្ដើមជាមួយនឹងលេខ ១០០០ ខណៈដែលសំណុំរឿងដែលប្ដឹងដោយបុរសនឹងចាប់ ផ្ដើមដោយលេខ ៥០០០ (ដូចជា ៥០០០. ៥០០១. ៥០០២. ៥០០៣)។ ធ្វើរបៀបនេះ នៅពេលដែលយើងឃើញលេខចាប់ផ្ដើមដោយលេខ "១" យើងនឹងដឹងយ៉ាងរហ័សថា វាជារឿងដែលប្ដឹងដោយស្ត្រី ហើយរឿងណាចាប់ផ្ដើមដោយលេខ "៥" វាជាសំណុំរឿងដែលប្ដឹងដោយបុរស។ នេះគ្រាន់តែជាការធ្វើអោយជាក់លាក់ក្នុងបរិបទនៃសំណុំរឿងរបស់ស្ត្រី និងបុរសតែប៉ុណ្ណោះ ចំពោះលេខសំណុំរឿង វានឹងកើនឡើងតាមលំដាប់ (ដូចជាសំណុំរឿងមានលេខ ១០០០ បន្ទាប់មក លេខ ១០០១ ១០០២... ទៅតាមសំណុំរឿងជាក់ស្ដែងដែលបញ្ជូនមកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់)។

*ឧទាហរណ៍ :*

១០តយ១០០១ / យិន ប៊ុនលី-មុន សុភាព / វិវាទដីធ្លី-វិវាទបញ្ហាគ្រួសារ

| | | |
|---|---|---|
| ១០តយ១០០១ | = | ជាលេខយោងសំណុំរឿង |
| ១០ | = | ២០១០ ឆ្នាំ នៃសំណុំរឿង |
| តយ | = | គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ ត្រែងត្រយឹង |
| ១០០១ | = | លេខសំណុំរឿងនៃសំណុំរឿងប្ដឹងដោយស្ត្រី |

យិន ប៊ុនលី-មុន សុភាព = ឈ្មោះរបស់ភាគីដែលពាក់ព័ន្ធ។ ឈ្មោះដំបូង គឺជាភាគីដើមបណ្ដឹងដែលនាំយករឿងទំនាស់មកកាន់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់។ ប្រសិនបើមានភាគីទំនាស់លើសពីពីរនាក់ លោកអ្នកគួរបន្ថែមឈ្មោះទាំងនោះផងដែរ ទៅលើផ្លាកសំគាល់របស់សំណុំរឿង។

វិវាទដីធ្លី និងវិវាទបញ្ហាគ្រួសារ = នេះបង្ហាញថា មានបញ្ហាទាំងពីរ គឺ ដីធ្លី និងបញ្ហាគ្រួសារ ហើយត្រូវបានចាត់ចំណាត់ថ្នាក់ទៅជាពីរប្រភេទដូចនេះឯង។ ជាថ្មីម្ដងទៀត សំណុំរឿងនានាអាចមានច្រើនជាងមួយប្រភេទ។

លេខសំគាល់ដែលបានលើកឡើងខាងលើទាំងនេះ គួរត្រូវដាក់នៅខាងចំហៀងនៃគម្របឯកសារ ដូចនេះ គេអាចមើលឃើញវាច្បាស់ដោយមិនចាំបាច់បើកសំណុំឯកសារ។ ការប្រើប្រាស់ការដាក់តាមលំដាប់នេះអាចផ្តល់ភាពងាយស្រួលយ៉ាងច្រើនទៅដល់សមាជិកគណៈកម្មាធិការ ក្នុងការរកព័ត៌មានបានយ៉ាងរហ័សពីលេខយោងសំណុំរឿងនោះ។

## ៤.១.៣. ការដាក់លេខរៀងសំណុំរឿង

សំណុំរឿង ត្រូវតែដាក់លេខរៀងដោយរៀបតាមលំដាប់អក្សរទៅតាមឈ្មោះរបស់ភាគី និងបែងចែកដាច់ពីគ្នា រវាងសំណុំរឿងប្តឹងដោយបុរស និងស្ត្រី។ វាគួរមានប្រអប់មួយដោយមានតែសំណុំរឿងរបស់ស្ត្រី និងប្រអប់មួយទៀតមានតែសំណុំរឿងរបស់បុរស។ (សំណុំរឿងស្ត្រី គឺជាសំណុំរឿងដែលអាចយកមកប្តឹងនៅគណៈកម្មាធិការដោយស្ត្រី ឬក៏នាំយកមកគណៈកម្មាធិការដោយបុរស ប៉ុន្តែទាក់ទិនទៅនឹងរឿងក្តីមួយ ដែលមានការផ្តោតទៅលើ "យេនឌ័រ" ដូចជារឿងក្តីអំពីអំពើហិង្សាក្នុងគ្រួសារ និងលែងលះជាដើម)។ ការបង់លេខរៀងទៅលើសំណុំរឿង គឺធ្វើតាមលំដាប់អក្សរ ហើយផ្តល់នូវការផ្ទៀងផ្ទាត់ទៅវិញទៅមករវាងឈ្មោះរបស់ភាគីវិវាទ និងលេខសំណុំរឿង។ ខុសពីការចុះបញ្ជីសំណុំរឿង ការដាក់លេខរៀងមិនកត់ត្រាចូលនូវកំណត់ត្រាតាមលំដាប់របស់សំណុំរឿងទេ។ វាគ្រាន់តែតម្រូវអោយមានការបន្ថែមព័ត៌មាននៅពេលដែលមានភាគីទំនាស់ត្រូវបានបន្ថែម ឬដកចេញពីសំណុំរឿងតែប៉ុណ្ណោះ។

## ៤.១.៤. ការបង្កើតប្រអប់សំណុំរឿង

ប្រអប់សំណុំរឿងមួយ គួរត្រូវបានបង្កើតឡើងនៅពេលចុះបញ្ជីសំណុំរឿងនីមួយៗ។ ប្រអប់សំណុំរឿងនេះ គួរមាននូវឯកសារនាពេលបច្ចុប្បន្ន និងពេលអនាគត ដែលទាក់ទិនទៅនឹងសំណុំរឿង។ ឯកសារទាំងនោះ គួរត្រូវដាក់លេខរៀង និងមានពណ៌ធម្មជាតិ ដែលអាចធ្វើអោយគណៈកម្មាធិការធ្វើការស្វែងរកសំណុំឯកសារដែលពួកគេត្រូវការបានយ៉ាងលឿនបំផុត។ នៅក្នុងប្រអប់ក្រដាសរាល់ឯកសារទាំងឡាយ គួរត្រូវរៀបចំទៅតាមលំដាប់នៃកាលបរិច្ឆេទនៃការចងក្រងនោះ។

នៅខាងមុខនៃផ្នែកខាងក្នុងរបស់សំណុំឯកសារនីមួយៗ គួរភ្ជាប់នូវព័ត៌មានដូចតទៅ :

# បញ្ជីផ្ទៀងផ្ទាត់សង្ខេប នៅខាងក្នុងគំរបសំណុំឯកសារ ៖

លេខយោងសំណុំរឿង ៖
ឈ្មោះរបស់ភាគីម្ចាស់ដើមបណ្តឹង ៖
ឈ្មោះរបស់ភាគីចុងចម្លើយ ៖
ភេទ មុខរបរ អាយុ ៖
ទីកន្លែង ៖ (ឈ្មោះ ភូមិ ឃុំ ស្រុក ខេត្ត)
កាលបរិច្ឆេទ ៖
វិធានការដែលត្រូវធ្វើ ៖ ពិនិត្យទៅលើជំហានទីមួយៗ តើវាត្រូវបានបំពេញឬនៅ និងអនុវត្តវាទៅលើសំណុំរឿង (ធ្វើអោយអ្នកដែលបើកសំណុំរឿង បានដឹងអំពីដំណាក់កាលរបស់សំណុំរឿងនាពេលបច្ចុប្បន្ន)

- ☑ វិវាទដំបូង ដែលបានប្តឹងមកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់
- ☐ លិខិតអញ្ជើញ អោយមកចូលរួមធ្វើការសម្រុះសម្រួល
- ☐ លិខិតអញ្ជើញ ត្រូវបានទទួល-កំពុងរង់ចាំការសម្រុះសម្រួល
- ☐ វគ្គសម្រុះសម្រួលលើកទី ១ បានធ្វើហើយ
- ☐ វគ្គសម្រុះសម្រួលលើកទី ២ បានធ្វើហើយ
- ☐ វគ្គសម្រុះសម្រួលបន្ថែមទៀត បានធ្វើហើយ
- ☐ ការសម្រុះសម្រួលបានបញ្ចប់
- ☐ ការផ្តល់យោបល់ផ្នែកច្បាប់បានផ្តល់អោយអំពីជំរើសផ្សេងៗ
- ☐ ភាគីទំនាស់បានឈានដល់កិច្ចព្រមព្រៀង
- ☐ កិច្ចព្រមព្រៀង ត្រូវបានចុះហត្ថលេខាដោយភាគីទាំងពីរជាសញ្ញានៃគោលបំណងល្អ
- ☐ ភាគីទំនាស់មិនបានឈានទៅដល់កិច្ចព្រមព្រៀង
- ☐ ភាគីទំនាស់យកសំណុំរឿងទៅមណ្ឌលសេវាកម្មយុត្តិធម៌ ឬសាលាដំបូង
- ☐ សំណុំរឿងមិនបានយកទៅមណ្ឌលសេវាកម្មយុត្តិធម៌ ឬសាលាដំបូងទេ

មតិយោបល់បន្ថែម ៖

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

វាជាការសំខាន់ណាស់ សម្រាប់អ្នកដែលនាំយកសំណុំរឿងមកកាន់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ បានយល់ដឹងអំពីជំហានទីមួយៗនៃដំណើរការនូវអ្វីដែលកំពុងកើតមានឡើង និងសំខាន់ជាងនេះទៅទៀត គឺពួកគេបានជ្រាបយ៉ាងពេញលេញនូវអ្វីដែលខ្លួនបានចុះហត្ថលេខា ហើយនៅពេលណាដែលពួកគេផ្តិតស្នាមមេដៃទៅលើឯកសារទាំងឡាយរបស់គណៈកម្មាធិការដោះស្រាយទំនាស់។ ធ្វើដូចនេះ ដើម្បីធានានូវតម្លាភាពនៃដំណើរការរបស់គណៈកម្មាធិការដោះស្រាយទំនាស់ និងការពារប្រឆាំងទៅនឹងបញ្ហាដែលកើតមានឡើងនាពេលក្រោយ ដែលអាចកើតមានឡើងពីជនណាមួយដែលអះអាងថា ខ្លួនពុំបានយល់ដឹងច្បាស់អំពីដំណើរការរបស់គណៈកម្មាធិការ។

នៅពេលសំណុំរឿងមួយ ត្រូវបានដោះស្រាយហើយដោយការសម្រុះសម្រួល និងមានការព្រមព្រៀង ឬចង្អុលបង្ហាញនីតិវិធីបន្ត សំណុំឯកសារនោះត្រូវកំណត់ចំណាំជាមួយនឹងសញ្ញាខ្វែងនេះ ⊗ នៅលើគំរបដូចនេះ វាត្រូវបានគេសំគាល់ចំណាំថា វាជាសំណុំរឿងដែលត្រូវបានបិទ ឬបានទទួលជោគជ័យហើយ។

# ៥ ការទទួលសំណុំរឿងពិសេស

## ៥.១. កំណត់នូវសំណុំរឿងដែលអាចធ្វើការសម្រុះសម្រួលបាន

រាល់សំណុំរឿងទាំងអស់ ពុំមែនអាចដោះស្រាយបានតាមរយៈការសម្រុះសម្រួលទាំងអស់ទេ។ ឧទាហរណ៍ ការដោះស្រាយទំនាស់ជម្លោះតូចតាចរវាងអ្នកភូមិអាចធ្វើការសម្រុះសម្រួលបាន។ ក៏ប៉ុន្តែទំនាស់ដែលពាក់ព័ន្ធទៅនឹងរឿងដីសម្បទាន ឬក៏ពាក់ព័ន្ធទៅនឹងទំនាស់រវាងបុគ្គល និងមន្ត្រីរាជរដ្ឋាភិបាល ឬក៏ក្រុមហ៊ុនឯកជន ជាការល្អប្រសើរ ដែលត្រូវបញ្ជូនទៅតុលាការ និងមិនអាចធ្វើការដោះស្រាយដោយប្រើប្រាស់ការសម្រុះសម្រួលនៅកម្រិតថ្នាក់ឃុំ សង្កាត់បានទេ។

ការវាយតម្លៃទៅលើសំណុំរឿង ដែលប្តឹងមកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ និងកំណត់ទៅលើរបៀបចាត់ការសំណុំរឿង ហើយថា តើសំណុំរឿងនោះអាចធ្វើការសម្រុះសម្រួលនៅកម្រិតថ្នាក់ឃុំ សង្កាត់ ឬអត់ ជាការងារដ៏លំបាកមួយរបស់សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់។ ទំនាស់នីមួយៗមានស្ថានភាពខុសគ្នា ហើយភាគីទំនាស់ក៏ឆ្លើយតបទៅលើស្ថានភាពទំនាស់របស់ពួកគេខុសគ្នា គឺជាអ្វីដែលយើងអាចគិតទុកជាមុនបាន។ ក្នុងករណីមានចម្ងល់ថា តើគណៈកម្មាធិការដោះស្រាយទំនាស់មាន ឬមិនមាន "សិទ្ធិ" ដើម្បីចាត់ការទៅលើសំណុំរឿងជាក់លាក់ណាមួយ សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ គួរស្វែងរកគំនិតយោបល់ពីលោកមេឃុំ ឬប្រធានមណ្ឌលសេវាកម្មយុត្តិធម៌ស្រុក ក្រុង។

សំណុំរឿងទំនាស់ដែលមិនអាចធ្វើការសម្រុះសម្រួល គឺមាន :

- សំណុំរឿងដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ដូចជា ការរំលោភ ឃាតកម្មជាដើម
- សំណុំរឿង ដែលភាគីមិនមានឆន្ទៈចូលរួមដោយស្ម័គ្រចិត្តនៅក្នុងការសម្រុះសម្រួល
- សំណុំរឿងដែលភាគីមួយ ឬទាំងពីរបានតាំងចិត្តថា នឹងប្តឹងទៅកាន់តុលាការ
- សំណុំរឿង ដែលមានទំនាស់ផលប្រយោជន៍រវាងភាគី និងអ្នកសម្រុះសម្រួល
- សំណុំរឿងដែលអាជ្ញាធរមានសមត្ថកិច្ចណាមួយកំពុងដោះស្រាយ ឬចាត់ការ
- ទំនាស់ដែលច្បាប់បានប្រគល់ ឬកំណត់យ៉ាងច្បាស់ទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចផ្សេង។

## ៥.២. ការសម្រុះសម្រួលលើករណីរឿងលែងលះ

ផ្នែកនេះផ្តោតទៅលើការស្នើសុំលែងលះអោយបានពិស្តារ។ រឿងលែងលះ គឺទំនងជារឿងដែលមានភាពលំបាកបំផុតក្នុងចំណោមរឿងលំបាកជាច្រើន ដែលត្រូវដោះស្រាយដោយគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ប្រសិនបើរឿងនោះ ត្រូវបានគេប្តឹងឡើងដោយសារមូលហេតុចេញមកពីអំពើហិង្សានៅក្នុងគ្រួសារ។ តើគួរធ្វើ ឬមិនធ្វើការសម្រុះសម្រួលទៅលើរឿងទាំងនេះ ឬក៏ផ្តល់នូវដំបូន្មានផ្នែកច្បាប់ទៅលើនីតិវិធីនៃការលែងលះ ដើម្បីបំរើសេវាសម្រុះសម្រួលទៅដល់ភាគីទំនាស់អោយអស់ពីចិត្ត។ សមាជិកគណៈកម្មាធិការគួរយល់ដឹងអោយបានច្បាស់លាស់អំពីច្បាប់ និងនីតិវិធីនានា ដែលកំពុងអនុវត្តនៅកម្ពុជាទាក់ទិនទៅនឹងការលែងលះ និងអំពើហិង្សាក្នុងគ្រួសារផងដែរ។

យុត្តាធិការ (អំណាចតុលាការ) ក្នុងរឿងលែងលះ គឺស្ថិតនៅលើសាលាដំបូង ដូចនេះ សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ មន្ត្រីមណ្ឌលសេវាកម្មយុត្តិធម៌ថ្នាក់ស្រុក ក្រុង ឬអាជ្ញាធរមូលដ្ឋានពុំមាននីត្យានុកូលភាព (អំណាចផ្លូវច្បាប់) ដើម្បីសម្រេចលើរឿងលែងលះនោះទេ។ ការសម្រុះសម្រួលរវាងភាគី ដែលភាគីម្ខាងស្វែងរកការលែងលះ គឺទំនងអាចធ្វើការសម្រុះសម្រួលទៅបាន *ប្រសិនបើមានក្តីសង្ឃឹមខ្លះក្នុងការធ្វើអោយមានការសម្រុះសម្រួល ឬក៏ភាគីទាំងអស់ មានចំណាប់អារម្មណ៍ក្នុងការពិភាក្សាទៅលើទំនាស់។ ប្រសិនបើភាគីទំនាស់ម្ខាងទទូចសុំការលែងលះ គណៈកម្មាធិការមិនគួរសម្រុះសម្រួលសំណុំរឿងនេះទេ។ គណៈកម្មាធិការ ត្រូវជំរាបប្រាប់ភាគីទាំងពីរអំពីនីតិវិធីនៃការលែងលះ ហើយធ្វើការណែនាំពួកគេអោយទៅរកអ្នកជំនួយផ្នែកច្បាប់ ឬទៅតុលាការខេត្ត ឬក្រុង។*

ផ្អែកទៅតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ មាត្រា ៣៩ ចែងអំពីមូលហេតុនៃការលែងលះមាន :

១. ការចុះចោលលំនៅសង្វាសដោយឥតមូលហេតុត្រឹមត្រូវ ហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ និងទំនុកបំរុងកូនសោះ។

២. វាយដំឃោរឃៅ ធ្វើទុក្ខបុកម្នេញ ប្រមាថមើលងាយធ្ងន់ធ្ងរចំពោះសហព័ទ្ធ ឬចំពោះបុព្វញាតិរបស់សហព័ទ្ធនេះ។

៣. មានចរិយាផ្ទុយពីសីលធម៌ ឬប្រព្រឹត្តអនាចារ

៤. អពលានុភាពនៃលិង្គ

៥. បែកគ្នាអស់រយៈជាង ១ ឆ្នាំ

*ហេតុផល ទី ២ និង ទី ៣ អាចអនុវត្តទៅលើករណីអំពើហិង្សានៅក្នុងគ្រួសារ។*

*កំណត់ចំណាំ:*

*នៅពេលខ្លះ គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ អាចធ្វើការសម្រុះសម្រួលលើករណីដែលភាគីទាមទារចង់ធ្វើការលែងលះបាន ប៉ុន្តែសម្រាប់តែនៅពេលដែលភាគីបង្ហាញច្បាស់លាស់ថា គេប្រាកដជាចង់ធ្វើការសម្រុះសម្រួលរឿងវិវាទរបស់គេ មុននឹងដាក់ពាក្យបណ្តឹងទៅតុលាការ។ វាអាចបញ្ជាក់ថា ភាគីកំពុងស្វែងរកការលែងលះក្នុងគោលបំណង ដើម្បីដាក់សម្ពាធទៅលើប្តី ឬប្រពន្ធតែប៉ុណ្ណោះ។ ប៉ុន្តែសមាជិកគណៈ-កម្មាធិការដោះស្រាយទំនាស់ ត្រូវតែធ្វើអោយច្បាស់លាស់ថា ភាគីវិវាទពិតជាមានបំណងចង់អោយមានការសម្រុះសម្រួលលើរឿងលែងលះរបស់គេពិតប្រាកដមែន។ ការសម្រុះសម្រួលអាចដំណើរការទៅបានល្អបំផុតតាមរយៈការប្រជុំជាសម្ងាត់ ហើយអ្នកសម្រុះសម្រួល ត្រូវនិយាយជាមួយភាគីវិវាទម្នាក់ម្តងៗជាឯកជន ដើម្បីស្វែងយល់អោយបានស៊ីជម្រៅពីអារម្មណ៍ ផលប្រយោជន៍ និងសេចក្តីត្រូវការពិតប្រាកដរបស់គេ។*

## ៥.៣. ការសម្រុះសម្រួលសំណុំរឿងអំពើហិង្សាក្នុងគ្រួសារ

ករណីអំពើហិង្សានៅក្នុងគ្រួសារដែលមានលក្ខណៈជាបទឧក្រិដ្ឋ សមាជិកគណៈកម្មាធិការមិនអាចធ្វើការសម្រុះសម្រួលបានទេ ប៉ុន្តែជាការជំនួសវិញ ពួកគេគួរតែចង្អុលបង្ហាញនីតិវិធីបន្តដល់ភាគីទំនាស់អោយទៅរកតុលាការ ឬក៏មន្ត្រីនគរបាលដោយផ្ទាល់តែម្តង។

**មាត្រាទី ១៧ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ បានចែងថា:**

ក្នុងការចូលរួមអនុវត្តនីតិវិធីព្រហ្មទណ្ឌជាធរមាន អាជ្ញាធរមានសមត្ថកិច្ចពុំអាចធ្វើអន្តរាគមន៍ដើម្បីសម្រុះសម្រួល ឬផ្សះផ្សាបទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈជាបទឧក្រិដ្ឋ ឬមជ្ឈិមធ្ងន់បានទេ។

គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ គួរផ្តល់ព័ត៌មានដែលពាក់ព័ន្ធទាំងឡាយឱ្យបានដល់ភាគីទំនាស់ ដើម្បីឱ្យភាគីបានយល់ដឹងដោយពេញលេញអំពីនីតិវិធីឆ្ពោះទៅកាន់តុលាការ។ ទាំងនេះ គឺជាព័ត៌មានដែលពាក់ជាមួយនឹងផ្លូវច្បាប់មួយចំនួនខាងក្រោមនេះ:

### ដីកាការពារសម្រាប់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ

តាមមាត្រា ១៦ និង ២៣ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលអនុញ្ញាតអោយជនរងគ្រោះ អាចធ្វើបណ្តឹងទៅសាលាដំបូងស្នើសុំដីកាការពារដោយតុលាការ។ ប្រសិនបើទទួលបានដីកាការពារពីតុលាការ ដីកានេះមានអំណាចដាក់បន្ទុកទៅលើអ្នកប្រព្រឹត្តិបទល្មើស អាជ្ញាធរ និងអ្នកផ្សេងទៀតដែលពាក់ពន្ធ័។

*យោងតាមមាត្រា ២៣ ដីកាការពារមានពីរដំណាក់កាល :*

១. ដំណាក់កាលទី ១ ហៅថា ដីកាការពារបណ្តោះអាសន្នដែលមានរយៈពេល ២ (ពីរ) ខែ ចេញក្នុងពេលដែលមានអាសន្នពីអំពើហិង្សាក្នុងគ្រួសារភ្លាមៗ។

២. ដំណាក់កាលទី ២ ហៅថា ដីកាការពារមានរយៈពេល ៦ (ប្រាំមួយ) ខែ ចេញក្នុងពេលដែលតុលាការកំពុងស៊ើបអង្កេតមិនទាន់ជំនុំជម្រះ ឬមុនពេលចេញសាលក្រមស្ថាពរ។

## ការស្នើសុំធ្វើការលែងលះតាមផ្លូវច្បាប់

ចំពោះករណីរឿងលែងលះ មានតែតុលាការខេត្ត ក្រុងទេ ដែលអាចផ្តល់នូវសេចក្តីសម្រេចបាន។ ការចេញសេចក្តីសម្រេចប្រភេទផ្សេងទៀតនៃការលែងលះឱ្យភាគីក្រៅពីតុលាការ គឺខុសច្បាប់។

ប្រសិនបើសំណើនៃការលែងលះ ត្រូវធ្វើឡើងដោយភាគីទាំងពីរ តុលាការអាចផ្តល់សេចក្តីសម្រេចលើការលែងលះនោះ ប្រសិនបើរកឃើញថា សំណើនៃការលែងលះ គឺធ្វើឡើងដោយស្ម័គ្រចិត្ត ឬដោយគ្មានការបង្ខិតបង្ខំ (មាត្រា ៥៨ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ)។

ប្រសិនបើសំណើនៃការលែងលះនោះ ត្រូវបានស្នើឡើងដោយភាគីតែម្ខាង តុលាការអាចផ្តល់នូវការលែងលះបាន តែក្នុងករណីដែលបន្ទាប់ពីធ្វើការស៊ើបអង្កេតរកឃើញថា មានកាលៈទេសៈធ្ងន់ធ្ងរដែលបង្ហាញថាភាគីទាំងពីរមិនអាចរួមរស់ជាមួយគ្នាបន្តទៅទៀតបាន (មាត្រា ៣៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ)។ ប្តី ឬប្រពន្ធ អាចប្តឹងសុំលែងលះគ្នាបាន កាលបើមានមូលហេតុគ្រប់គ្រាន់បញ្ជាក់ថា ខ្លួនពុំអាចរួមរស់ជាមួយគ្នាតទៅទៀតបាន។

នីតិវិធីសម្រាប់ការលែងលះមានចែងនៅក្នុងជំពូក ៥ កថាខណ្ឌ ៥.២។

***សូមកត់ចំណាំថា :*** *បុរសជាប្តី មិនត្រូវបានអនុញ្ញាតអោយធ្វើការស្នើសុំលែងលះទេ ប្រសិនបើប្រពន្ធរបស់ខ្លួនកំពុងពរពោះរហូតដល់រយៈពេល ១ ឆ្នាំ បន្ទាប់ពីកូននោះបានកើត។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីអាចស្នើសុំការលែងលះពីប្តីរបស់ខ្លួនខណៈពេលដែលគាត់ពរពោះ។*

*ដំណើរការលែងលះ តាមរយៈតុលាការមានដូចតទៅ :*

១. បណ្តឹងសុំលែងលះគ្នា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីមូលហេតុដែលនាំអោយមានការលែងលះគ្នា។ បណ្តឹងនោះ ត្រូវដើមចោទយកទៅជូនតុលាការខេត្ត-ក្រុងផ្ទាល់ក៏បាន ឬជូនគណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់ខាងលំនៅរបស់ចុងចម្លើយដោយខ្លួនឯងផ្ទាល់ក៏បាន។ ក្នុងករណី ខាងក្រោមនេះ គណៈកម្មាធិការប្រជាជនប្រជាជនឃុំ ឬសង្កាត់ ត្រូវធ្វើការផ្សះផ្សាក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយពីបានទទួលពាក្យបណ្តឹង។ បើការផ្សះផ្សាពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅតុលាការប្រជាជនខេត្ត-ក្រុង។

២. តុលាការខេត្ត-ក្រុង ត្រូវអញ្ជើញអ្នកប្ដឹងអោយចូលមក ហើយសម្រួលយ៉ាងណាតាមដែលខ្លួនយល់ឃើញ ដើម្បីបញ្ចុះបញ្ចូលចិត្តអ្នកនោះអោយឈប់ប្ដឹង លើកលែងតែតុលាការខេត្ត-ក្រុង យល់ឃើញថា ពាក្យសុំលែងលះគ្នានេះ មានអង្គហេតុធ្ងន់ធ្ងរណាស់។

៣. ក្រោយពីពេលបានទទួលបណ្ដឹងសុំលែងលះ បើយល់ឃើញថា ការចាំបាច់តុលាការប្រជាជនខេត្ត-ក្រុង អាចចាត់វិធានការបណ្ដោះអាសន្នបាន ដូចជា ការបំបែកលំនៅប្ដីប្រពន្ធ ការអោយថែរក្សាកូន ថែរក្សាទ្រព្យសម្បត្តិ ការផ្ដល់អាហារកិច្ច។

៤. បន្ទាប់ពីការផ្សះផ្សាលើកទី ១ ភាគីដើមចោទ និងចុងចម្លើយ ហើយនៅតែពុំបានសម្រេចនូវកិច្ចព្រមព្រៀង តុលាការខេត្ត-ក្រុង អាចធ្វើការផ្សះផ្សាជាលើកទី ២ បាន។

៥. ប្រសិនបើចុងចម្លើយបានទទួលដីកាអញ្ជើញដោយត្រឹមត្រូវ ហើយនៅតែមិនព្រមចូលខ្លួនមកកាន់តុលាការប្រជាជនខេត្ត-ក្រុង ទាំងលើកទី១ ទាំងលើកទី២ ដោយគ្មានមូលហេតុ នោះត្រូវចាត់ទុកថា មិនព្រមសះជានឹងគ្នា។

៦. ប្រសិនបើអ្នកដែលមិនបានមកតាមដីកាអញ្ជើញលើកទី ១ មិនមែនជាអ្នកមិនបានមកលើកទី ២ ទេ តុលាការប្រជាជនខេត្ត-ក្រុង ត្រូវអញ្ជើញភាគីនោះមកផ្សះផ្សាជាលើកទី៣។

៧. ប្រសិនបើដើមបណ្ដឹងទទួលបានលិខិតអញ្ជើញហើយ ហើយខកខានមិនបានបង្ហាញខ្លួននៅតុលាការដោយពុំមានការពន្យល់ត្រឹមត្រូវ ឬក៏ស្នើអោយរំសាយសវនការទេនោះនឹងចាត់ទុកថា បានដកពាក្យបណ្ដឹង ហើយតុលាការអាចចេញបញ្ជាលុបចោលពាក្យបណ្ដឹងនោះ។

៨. ប្រសិនបើការផ្សះផ្សាពុំបានទទួលជោគជ័យទេ តុលាការអាចចេញលិខិតកោះអញ្ជើញអោយភាគីទាំងប្រពន្ធ និងប្ដីមកកាន់តុលាការ ដើម្បីកាត់សេចក្ដីតែម្ដង

៩. បើចុងចម្លើយប្រកែកថា សេចក្ដីដែលប្ដឹងពីខ្លួននោះមិនពិតទេ តុលាការប្រជាជនត្រូវបញ្ជាឱ្យធ្វើការអង្កេតស៊ើបសួរ។

១០. ក្នុងករណីសុំលែងលះដោយឯកតោភាគី បើក្រោយពីការអង្កេតស៊ើបសួរឃើញថា ស្ថានភាពរវាងប្ដីប្រពន្ធមានភាពធ្ងន់ធ្ងរ ការរួមរស់ជាមួយគ្នាមិនអាចពន្យារយូរបាន គោលបំណងអាពាហ៍ពិពាហ៍លែងបានសម្រេច តុលាការប្រជាជនត្រូវសម្រេចឱ្យលែងលះគ្នា។ (មាត្រា ៥៩ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ)។

***សំគាល់ :*** *រយៈពេលរវាងការផ្សះផ្សានីមួយៗ គួរមានរវាងយ៉ាងហោចណាស់ ១ ខែ និងយ៉ាងច្រើន ២ ខែ។*

១១. កាលបើសាលក្រមលែងលះជាសាលក្រមស្ថាពរ តុលាការប្រជាជនខេត្ត-ក្រុង ត្រូវចាត់ចែងឱ្យចំលងសេចក្ដីវិនិច្ឆ័យនៃសាលក្រមស្ថាពរនោះ ចុះនៅរឹមទំព័រនៃសំបុត្រអាពាហ៍ពិពាហ៍ដែលត្រូវរំលាយ។

នៅពេលដែលអ្នកបានជំរាបភាគីអំពីជំហាននានា ដែលមានរួចហើយ *អ្នកគួរ ឬមិនគួរ* បញ្ចុះបញ្ចូលទៅលើការសម្រេចចិត្តរបស់ពួកគេនោះទេ។ អ្នកគ្រាន់តែធ្វើការផ្ដល់ព័ត៌មាន ហើយអ្វីៗវាអាស្រ័យទៅលើពួកគេជាអ្នកធ្វើការសម្រេចចិត្តចុងក្រោយ។

# ៥.៤. សំណុំរឿងទាក់ទិននឹងយេនឌ័រ

គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ត្រូវបង្កើតឡើងដើម្បីសិទ្ធិទទួលបានយុត្តិធម៌សម្រាប់អ្នកក្រីក្រ ស្ត្រី និងជនជាតិភាគតិច។ ការស្រាវជ្រាវមួយនៅកម្ពុជាបានបង្ហាញថា ស្ត្រីមានឱកាសតិចតួច ដើម្បីទទួលបាននូវយុត្តិធម៌។ ហេតុដូច្នេះ គណៈកម្មាធិការដោះស្រាយទំនាស់ ត្រូវផ្តល់នូវអាទិភាពសម្រាប់អ្នកទាំងនោះ ហើយសមាជិកគណៈកម្មាធិការគួរយកចិត្តទុកដាក់ទៅលើបញ្ហាយេនឌ័រនៅគ្រប់ទិដ្ឋភាពទាំងអស់ នៃការងាររបស់ខ្លួន។

គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ដែលទទួលបានសំណុំរឿងពាក់ព័ន្ធជាមួយស្ត្រី គួរអនុវត្តនី: ១) ផ្តល់អាទិភាពលើសសំណុំរឿងផ្សេងៗ ២) ត្រូវយកចិត្តទុកដាក់ខ្ពស់ ៣) រាល់ការងារទាំងឡាយ ត្រូវបង្កប់នូវការរំឭកដល់យេនឌ័រខ្ពស់។

ផ្នែកនេះនឹងលើកឡើងនូវគោលការណ៍ដែលទាក់ទិនទៅនឹងបញ្ហាយេនឌ័រ។ ដោយពិចារណាថា មានសំណុំរឿងជាច្រើនដែលត្រូវបាន និងកំពុងបញ្ជូនមកគណៈកម្មាធិការដោយផ្ទាល់តែម្តង ដែលទាក់ទិនទៅនឹងបញ្ហាយេនឌ័រ ដូចជា អំពើហិង្សាក្នុងគ្រួសារ វាជាការសំខាន់ណាស់ដើម្បីយល់ដឹង និងមានចំណេះដឹងជ្រៅជ្រះទៅលើច្បាប់នានា ដែលផ្តោតលើយេនឌ័រ ដើម្បីចែករំលែកព័ត៌មានទាំងនេះ ទៅដល់ភាគីដែលស្វែងរកការប្រឹក្សាយោបល់។ អ្នកអាចយោងទៅលើគោលការណ៍ណែនាំសម្រាប់ : ក) ការបញ្ជាក់ទៅលើរបៀបដោះស្រាយសំណុំរឿងពាក់ព័ន្ធទៅនឹងយេនឌ័រ ដែលត្រូវការយកចិត្តទុកដាក់ខ្លាំង ខ) ឯកសារយោងទៅលើពាក្យដែលពាក់ព័ន្ធទៅនឹងយេនឌ័រ គ) ឯកសារយោងអំពីច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

## ៥.៤.១. និយមន័យ យេនឌ័រ

**យេនឌ័រ** សំដៅទៅលើទំនាក់ទំនងដែលត្រូវបានបង្កើតឡើងដោយសង្គម រវាងស្ត្រី និងបុរស ហើយមានឥទ្ធិពលគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិតរស់នៅ : ផ្នែកសង្គម សេដ្ឋកិច្ច នយោបាយ វប្បធម៌ និងបរិស្ថាន។ តួនាទីយេនឌ័រមានភាពសកម្ម ហើយផ្លាស់ប្តូរទៅតាមពេលវេលា។ ដោយឡែក ភេទសំដៅទៅលើតែលក្ខណវិនិច្ឆ័យផ្នែកជីវសាស្ត្ររបស់បុរស និងស្ត្រី ដែលមានមកពីកំណើត។

**សមភាពយេនឌ័រ** សំដៅទៅលើភាពត្រឹមត្រូវយុត្តិធម៌សម្រាប់ស្ត្រី និងបុរស ដោយយោងទៅលើសេចក្តីត្រូវការរៀងៗខ្លួន។ នេះអាចរួមបញ្ចូលនូវការគោរពដោយស្មើគ្នា ឬការគោរពមានភាពខុសគ្នា ក៏ប៉ុន្តែដែលត្រូវចាត់ទុកថា សមមូលស្មើទៅនឹងសិទ្ធិ អត្ថប្រយោជន៍ កាតព្វកិច្ច និងឱកាសនានា។

**ទំនាក់ទំនងយេនឌ័រ** រួមមាន : តួនាទីយេនឌ័រ ភ្ជាប់ ហើយត្រូវបានបំពេញដោយស្ត្រី និងបុរស (ក្មេងស្រី និងក្មេងប្រុស) នៅក្នុងគ្រួសារ នៅក្នុងសហគមន៍ កន្លែងធ្វើការ និងសង្គម។ ឱកាស និងធនធាន (រួមមាន ធនធាន ធម្មជាតិ សេដ្ឋកិច្ច ច្បាប់ សង្គម និងអប់រំ) ដែលស្ត្រី និងបុរស អាចទទួលផលបាន ដើម្បីបំពេញតួនាទីរបស់ខ្លួន ហើយជាចុងក្រោយទៅលើការគ្រប់គ្រង ការសម្រេចចិត្ត ដែលស្ត្រី និងបុរស នៃធនធានទាំងនេះនៅក្នុងតួនាទីរៀងៗខ្លួន[៦]។

ចំណុចខាងលើនេះ មានភាពប៉ះពាល់ទៅលើសំណុំរឿង ដែលគណៈកម្មាធិការនឹងធ្វើការដោះស្រាយ។ វាមិនមែនអាចកើតឡើងគ្រប់តែពេលនោះទេដែលថា ភាគីទំនាស់ដែលប្តឹងរឿងរបស់ខ្លួនមកកាន់គណៈ-កម្មាធិការមានឋានៈនៅក្នុងសង្គមប្រហាក់ប្រហែលគ្នា ឬក៏មានអំណាចធ្វើការសម្រេចចិត្តស្មើគ្នា មិនថាចំពោះរឿងទាក់ទិនទៅនឹងទំនាស់អំពើហិង្សានៅក្នុងគ្រួសារ ឬក៏ទំនាស់ទៅលើដីធ្លី។ នៅប្រទេសកម្ពុជាយើង ក៏ដូចជានៅតាមបណ្តាប្រទេសផ្សេងដែរ ស្ត្រី និងក្មេងស្រី មានឱកាសតិចតួច ដោយសារតែអសមភាពយេនឌ័រនៅក្នុងសង្គម និងតម្លៃវប្បធម៌ និងជំនឿផ្សេងៗដែលអោយតម្លៃទៅលើបុរស ជាអ្នកដឹកនាំគ្រួសារ និងសង្គម (អ្នកធ្វើគោលនយោបាយអ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកគ្រួតត្រាធនធាន)[៣]។

៥.៤.២.ការពិចារណាទៅលើយេនឌ័រក្នុងការអនុវត្តជាក់ស្តែង :

- សំណុំរឿងរបស់ស្ត្រីនឹងត្រូវដាក់ដោយឡែកពីសំណុំរឿងផ្សេងៗទៀត និងត្រូវផ្តល់នូវប្រភេទលេខយោងជាក់លាក់មួយដែលធ្វើអោយមានភាពងាយស្រួល ដើម្បីរកព័ត៌មានបានរហ័សលើសំណុំរឿងទាក់ទិនទៅនឹងយេនឌ័រ (សូមមើលជំពូកទី ៤ កថាខណ្ឌ ៤.១) : ការទទួលសំណុំរឿងពិសេសនៅគណៈកម្មាធិការដោះស្រាយទំនាស់)
- នៅពេលណាក៏ដោយ ការទទួលដោះស្រាយរឿងទំនាស់របស់ស្ត្រីត្រូវប្រាកដថា ធ្វើការសាកសួរស្ត្រីដាច់ដោយឡែកពីប្តីរបស់គាត់ ឬពីបងប្អូនប្រុសរបស់គាត់ ដែលអាចមកជាមួយគាត់។ វាមានសារៈសំខាន់ផងដែរ ដែលអ្នកចាត់ការដោះស្រាយលើសំណុំរឿងដែលប្តឹងមកដោយស្ត្រីប្រកបដោយភាពម៉ត់ចត់ និងការព្យាយាម ដូចដែលអ្នកធ្វើឡើងចំពោះរឿងដែលប្តឹងដោយបុរសដែរ។
- វាមានសារៈសំខាន់ ដែលអ្នកត្រូវយកចិត្តទុកដាក់អោយបានខ្ពស់ទៅលើសំណុំរឿងរបស់ស្ត្រី ដូចដែលអ្នកបានធ្វើជាមួយនិងបុរសដូច្នេះដែរ
- នៅពេលណាដែលទំនាស់អំពីអំពើហិង្សាក្នុងគ្រួសារ ឬការរំលោភបំពានក្នុងគ្រួសារ ត្រូវបានប្តឹងមកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ គួរមានភាពប្រយ័ត្នប្រយែងដោយមិនត្រូវបង្ហាញអោយឃើញពីភាពលំអៀងសង្គមដែលអាចមាន ហើយមិនត្រូវធ្វើឱ្យស្ត្រីមានអារម្មណ៍ថា គាត់ត្រូវបានស្តីបន្ទោសទៅលើរឿងទំនាស់របស់គាត់។ អំពើហិង្សានៅក្នុងគ្រួសារ មិនគួរត្រូវបានទទួលយកថាជារឿងធម្មតា ដោយសមាជិកគណៈកម្មាធិការនោះទេ (ទោះបីជាសហគមន៍យល់ថា វាជារឿងធម្មតានៅក្នុងគ្រួសារក៏ដោយ) ហើយក៏មិនត្រូវប្រកាន់ជំហរថា អំពើហិង្សានៅក្នុងគ្រួសារ គឺជា "រឿងនៅក្នុងផ្ទះ" តែប៉ុណ្ណោះ ដែលគួរត្រូវបានរក្សាជាការសម្ងាត់ និងធ្វើការដោះស្រាយនៅក្នុងគ្រួសារ បើទោះបីណាវាប្រឆាំងទៅនឹងបំណងរបស់ស្ត្រីក៏ដោយ។

---

[២] "គោលការណ៍យេនឌ័រ" ឧបករណ៍គ្រប់គ្រងការអភិវឌ្ឍន៍ ៣, ការិយាល័យអភិវឌ្ឍន៍ប្រទេសស្វីស តំបន់ទន្លេមេគង្គ / SDC: ភ្នាក់ងារប្រទេសស្វីសសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការ, ២ អាចរកបាននៅលើគេហទំព័រ : http://www.deza.admin.ch/ressources/resource_en_24044.pdf ។

[៣] ឯកសារដដែល។

- ភាពអាណិតអាសូរ គួរត្រូវធ្វើឡើងទៅមនុស្សគ្រប់រូប ទាំងបុរស និងស្ត្រីដែលមកកាន់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ជាមួយរឿងទំនាស់ដែលមានភាពងាយរសើប ជាពិសេស រឿងទាក់ទិនទៅនឹងអំពើហិង្សា និងឧក្រិដ្ឋកម្ម។ ក៏ប៉ុន្តែភាពអាណិតអាសូរនេះ វាត្រូវតែធ្វើឡើងជាពិសេសចំពោះរឿងទំនាស់ណា ដែលនាំយកមកដោយស្ត្រីដោយសារតែពួកគេក្នុងចំនួនភាគច្រើនជាជនរងគ្រោះពីប្រភេទនៃរឿងទំនាស់នេះ។
- សមាជិកគណៈកម្មាធិការ គួរប្រើប្រាស់ខ្លឹមសារច្បាប់ជាតិ និងអន្តរជាតិ ដែលមាននៅក្នុងផ្នែកនេះ មិនគ្រាន់តែសម្រាប់ជាឯកសារយោងប៉ុណ្ណោះទេ តែថែមទាំងផ្តល់ព័ត៌មាន និងធ្វើការអប់រំទៅលើភាគីនានា ដែលស្វែងរកសេវាកម្មពីគណៈកម្មាធិការ។ រាជរដ្ឋាភិបាលបានអនុម័តច្បាប់ជាច្រើន ដែលបានចាត់ទុកអំពើហិង្សាប្រឆាំងនឹងស្ត្រីជាបទឧក្រិដ្ឋ។ ព័ត៌មាននេះ គួរជំរាបទៅដល់ទាំងភាគីរងគ្រោះ និងភាគីប្រព្រឹត្តិបទល្មើស ធ្វើដូចនេះ ដើម្បីចៀសវាងនិទ្ទណ្ឌភាព (អំពើគ្មានទោសពៃរ៍) របស់ជនល្មើស និងដើម្បីផ្តល់អំណាចទៅដល់ជនរងគ្រោះ ហើយសមាជិកគណៈកម្មាធិការអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មានដ៏សំខាន់នេះ។
- វប្បធម៌របស់ខ្មែរយើង គឺទោរទន់ទៅរកការផ្សះផ្សាគ្នាទៅលើរឿងទំនាស់ភាគច្រើន។ ខណៈពេលដែលទំនោរនេះមានប្រយោជន៍ក្នុងស្ថានភាពមួយចំនួន វាអាចមិនមានភាពសមរម្យក្នុងការជំរុញអោយមានការផ្សះផ្សាលើអ្វីៗទាំងអស់ ជាពិសេស ចំពោះរឿងដែលពាក់ព័ន្ធជាមួយអំពើហិង្សានៅក្នុងគ្រួសារ និងការវាយដំ រំលោភបំពានធ្ងន់ធ្ងរ។ សមាជិកគណៈកម្មាធិការ គួរត្រូវប្រយ័ត្នប្រយែងក្នុងការជំរុញអោយមានការផ្សះផ្សាប្រសិនបើមើលទៅឃើញថា ភាគីជាស្ត្រីហាក់ដូចជាមានភាពស្ទាក់ស្ទើរក្នុងចិត្តក្នុងការផ្សះផ្សានោះ។
- ស្ត្រីអាចនាំសំណុំរឿងមួយមកកាន់គណៈកម្មាធិការ ដោយមិនមែនជារឿងពាក់ព័ន្ធទៅនឹងយេនឌ័រ។ ឧទាហរណ៍ ប្រហែលជារឿងដែលពាក់ព័ន្ធជាមួយនឹងការលួចទ្រព្យសម្បត្តិ។ ទោះជាដូចនេះក៏ដោយ ដូចដែលមានភស្តុតាងកន្លងមកបានបង្ហាញ ជាទូទៅ រឿងទំនាស់ដែលប្តឹងដោយស្ត្រីមិនត្រូវបានយកចិត្តទុកដាក់អោយបានម៉ត់ចត់ ដូចទៅនឹងរឿងដែលប្តឹងដោយបុរសទេ ទោះជាកម្មវត្ថុបណ្តឹងនោះជាអ្វីក៏ដោយ។ នៅក្នុងហេតុផលនេះ សមាជិកគណៈកម្មាធិការ គួរត្រូវប្រឹងប្រែងរួមគ្នាដើម្បីធ្វើការធានាថា ករណីនេះមិនកើតមានឡើងទេ នៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់។

## ៥.៤.៣. សិទ្ធិស្ត្រី គឺជាសិទ្ធិមនុស្ស

សិទ្ធិមនុស្ស ត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញជាតិ សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងច្បាប់ប្រពៃណីអន្តរជាតិ។ ដើម្បីពិនិត្យទៅលើសិទ្ធិរបស់ស្ត្រីនៅតាមគ្រួសារ វាជាការចាំបាច់ក្នុងការរៀបចំនូវបញ្ជីមួយអំពីច្បាប់មាននៅក្នុងប្រទេសកម្ពុជា ព្រមទាំងមើលទៅលើកាតព្វកិច្ចរបស់រដ្ឋនៅក្រោមសន្ធិសញ្ញាអន្តរជាតិ អំពីសិទ្ធិមនុស្សដែលកម្ពុជាបានផ្តល់សច្ចាប័នរួចហើយ។

សម្រាប់ជាឯកសារយោងរបស់លោកអ្នក រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់មួយចំនួន ដែលលើកកម្ពស់ និងការពារសិទ្ធិស្ត្រីនៅក្រោមសិទ្ធិសញ្ញា ស្តីពីសិទ្ធិមនុស្សអន្តរជាតិដែលបានអនុម័ត។

ខាងក្រោមនេះជាច្បាប់ជាតិសំខាន់ៗ ដែលការពារសិទ្ធិស្ត្រី :

- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ (១៩៨៩)
- ច្បាប់ឯកពន្ធភាព(២០០៦)
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (២០០៥)
- ច្បាប់ព្រហ្មទណ្ឌអន្តរកាលរបស់អ៊ុនតាក់ (១៩៩២)
- ច្បាប់ការងារ (១៩៩៧)
- ច្បាប់ពន្លូតកូន (១៩៩៧)
- ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស (១៩៩៧)
- ច្បាប់សារព័ត៌មាន (១៩៩១)

បន្ថែមលើនេះ ខាងក្រោមនេះជាគោលនយោបាយសំខាន់ៗ ដែលផ្តោតលើការការពារស្ត្រី :

- នារីរតនៈ ១ (១៩៩៥)
- នារីរតនៈ ២ (២០០៥)
- ផែនការជាតិអភិវឌ្ឍន៍យុទ្ធសាស្ត្រ (២០០៦-២០១០)
- ផែនការសកម្មភាពជាតិការពារអំពើហិង្សាប្រឆាំងនឹងស្ត្រី (២០០៩)
- យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា (២០០៤)
- គោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់ប្រទេសកម្ពុជា- គោលដៅទី ៣ (២០០៣)
- វេទិកាក្រុងប៉េកាំង ដើម្បីសកម្មភាព (១៩៩៥)
- សេចក្តីថ្លែងការណ៍ជាសាកលអំពីសិទ្ធិមនុស្ស (១៩៤៨)
- កតិកាសញ្ញាស្តីពីការលុបបំបាត់ការរើសអើងគ្រប់រូបភាពប្រឆាំងទៅលើស្ត្រី (ស៊ីដ-១៩៧០)
- សេចក្តីថ្លែងការណ៍ពីការលុបបំបាត់ចោលអំពើហិង្សា ប្រឆាំងស្ត្រី (១៩៩៣)
- កតិកាសញ្ញាស្តីពីសិទ្ធិកុមារ (១៩៨៩)
- សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីជនជាតិភាគតិច

*សំគាល់: រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នទៅលើកិច្ចព្រមព្រៀងសិទ្ធិមនុស្សទាំងអស់ខាងលើនេះ ។*

### ៥.៤.៤. ឯកសារច្បាប់នានា : ផ្នែកយេនឌ័រ

សម្រាប់ជាឯកសារយោងទាក់ទងទៅនឹងទិដ្ឋភាពយេនឌ័រ គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ គួរសិក្សាស្វែងយល់លើឯកសារទាំងនេះដោយទៀងទាត់ ។

១. ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ

២. ច្បាប់ឯកពន្ធភាព

៣. ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ

៤. កតិកាសញ្ញាស្តីពីការលុបបំបាត់ការរើសអើងគ្រប់រូបភាពប្រឆាំងទៅលើស្ត្រី

៥. ឯកសារផ្សេងទៀត ពាក់ព័ន្ធទៅនឹងបរិបទយេនឌ័រនៅកម្ពុជា

- *យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា*
- *គោលដៅអភិវឌ្ឍន៍សហសវត្សរបស់ប្រទេសកម្ពុជា*
- *នារីរតនៈ ១ និង ២ និង៣*
- *រដ្ឋធម្មនុញ្ញ*

សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ គួរយល់ដឹងអោយបានច្បាស់ទៅលើឯកសារទាំងនេះ ដូចនេះ ពួកគេអាចផ្តល់នូវព័ត៌មាន និងប្រឹក្សាយោបល់ត្រឹមត្រូវទៅដល់អ្នកដែលស្វែងរកសេវាកម្មនៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ។

# ៦ បច្ចេកទេស និងគោលការណ៍នៃការសម្រុះសម្រួល

## ៦.១. ខ្លឹមសារទូទៅ

និយមន័យ : ការសម្រុះសម្រួល គឺជាការស្ម័គ្រចិត្ត ជាដំណើរការដែលពុំមានការចងភ្ជាប់នូវកាតព្វកិច្ច ដែលនៅក្នុងនោះ អ្នកសម្រុះសម្រួលគ្មានភាពលំអៀង និងមានភាពអព្យាក្រឹត្យ ដែលត្រូវជ្រើសតាំងឡើងរវាងភាគីទាំងពីរ ហើយជួយឱ្យភាគីទាំងនោះបានព្រមព្រៀងគ្នា[៦] ។

ការសម្រុះសម្រួលត្រូវបានគិតថា ជាយន្តការដោះស្រាយវិវាទដែលពុំមានចងភ្ជាប់នូវកាតព្វកិច្ច ។ វាជាដំណើរការដែលស្ម័គ្រចិត្ត ភាគីទំនាស់បានព្រមព្រៀងគ្នាធ្វើដូច្នេះ ដោយផ្តើមចេញពីឆន្ទៈដោយពុំមានការបង្ខិតបង្ខំ ។ វាមិនដូចគ្នានឹងចៅក្រម ឬអាជ្ញាកណ្តាលទេ អ្នកសម្រុះសម្រួលពុំមានអំណាចក្នុងការផ្តល់ដំណោះស្រាយចំពោះភាគីវិវាទឡើយ ។ ជាជំនួសនេះ ការងាររបស់អ្នកសម្រុះសម្រួល គឺបង្កើតលក្ខខណ្ឌដែលនៅក្នុងនោះភាគីទំនាស់អាចពិភាក្សា និងឈានទៅរកដំណោះស្រាយ ឬការសម្រេចចិត្តរបស់ពួកគេ ។ អ្នកសម្រុះសម្រួលមិនអាចផ្តល់ដំណោះស្រាយចំពោះភាគីទំនាស់ហើយត្រូវតែរក្សាភាពអព្យាក្រឹត្យនិងមិនលម្អៀង ។ដំណោះស្រាយមួយដែលកើតឡើងពីភាគីទំនាស់ខ្លួនគេ ហើយដែលត្រូវបានព្រមព្រៀងហើយនោះ គឺត្រូវបានប្រកាន់ខ្ជាប់ដោយភាគីទាំងពីរ ហើយស្ថិតស្ថេរយូរអង្វែងទៀតផង ។ អ្នកសម្រុះសម្រួលអាចជួយក្នុងការញែកមនុស្ស ឬភាគីទំនាស់ឱ្យចេញឆ្ងាយពីបញ្ហា និងពិភាក្សាដោយផ្ទាល់ឆ្ពោះទៅរកផលប្រយោជន៍ និងជម្រើសនានា ។

តួនាទីសំខាន់របស់អ្នកសម្រុះសម្រួល គឺត្រូវពិនិត្យមើលថា ការងារនោះបានអនុវត្តតាមដំណើរការនៃការសម្រុះសម្រួល ហើយបានសម្របសម្រួលការប្រាស្រ័យទាក់ទងគ្នាបានត្រឹមត្រូវហើយ ។ ដំណើរការនោះត្រូវតែរក្សាការសម្ងាត់ ហើយចំពោះការប្រជុំពិភាក្សា មិនត្រូវពិភាក្សាជាមួយអ្នកផ្សេងទៀត ដែលនៅក្រៅពីភាគីទំនាស់ទេ ។

អ្នកសម្រុះសម្រួលត្រូវប្រើវិធីសាស្ត្រផ្សេងៗគ្នា ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនៅក្នុងតួនាទីរបស់ខ្លួន ។ ការងារនេះនឹងត្រូវបានជ្រៀតជ្រែកដោយកត្តាផ្សេងៗ ដែលកើតឡើងដោយសារមនុស្សម្នាក់ៗ ដូចជា អាកប្ប-កិរិយាផ្ទាល់ខ្លួន កម្រិតវប្បធម៌ និងការហ្វឹកហ្វឺនអប់រំ បទពិសោធន៍ជីវិត និងការងារ ។ ការសម្រុះសម្រួលត្រូវបានចង្អុលប្រាប់វិញតាមរយៈការឆ្លុះបញ្ចាំងពីសកម្មភាពដែលបានធ្វើឡើង ។

---

[៦] King and Rendall, "ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ" CLEC, ទំព័រ ១០៨



*អ្នកសម្រុះសម្រួលជួយភាគីធ្វើការពិភាក្សាបញ្ហារបស់ពួកគេ*

*ការងារនេះ ផ្តល់នូវពេលវេលាបន្ថែមជាច្រើនដល់អ្នកសម្រុះសម្រួល ប៉ុន្តែក៏ជាការដែលបង្កឱ្យមានការទទួលខុសត្រូវយ៉ាងខ្ពស់ក្នុងការអនុវត្តការងារដោយមិនលម្អៀង និងប្រកបដោយវិជ្ជាជីវៈ ។*

## ៦.២. ការសម្រុះសម្រួលនៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

នៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ សមាជិកគណៈកម្មាធិការត្រូវបានរំពឹងថា នឹងមានតួនាទីជាអ្នកសម្រុះសម្រួលក្នុងកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្ពស់បំផុតឱ្យអស់ពីសមត្ថភាព។ ករណីជាច្រើនដែលបានលើកយកមកឱ្យសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់នឹងមានការប្រែប្រួល ហើយវាមានសារៈសំខាន់ណាស់ដែលសមាជិកនោះឆ្លើយតបនឹងករណីនីមួយៗផ្សេងៗគ្នា និងដោយវិធីដ៏សមរម្យបំផុត។ ផ្នែកនេះត្រូវបានរៀបចំឡើង ដើម្បីផ្តល់នូវគោលការណ៍ និងច្បាប់ជាមូលដ្ឋាន ដែលត្រូវប្រកាន់ខ្ជាប់ដោយហេតុថា ពួកគេត្រូវដើរតួនាទីជាអ្នកសម្រុះសម្រួលយ៉ាងអព្យាក្រឹត្យនៅចំពោះមុខភាគីទំនាស់។ ចំណុចសំខាន់ដែលត្រូវចងចាំគឺការសម្រុះសម្រួល លោក-អ្នកត្រូវធ្វើ*ការសម្របសម្រួល* (មិនមែននិយាយឱ្យគេថាតាមទេ) ដើម្បីឱ្យភាគីទំនាស់បានឈានចូលទៅរកកិច្ចព្រមព្រៀងមួយ។ អ្នកជួយឱ្យភាគីទាំងពីរបានទទួលយកនូវកិច្ចព្រមព្រៀងមួយដែលអាចទទួលយកបានពីសំណាក់ភាគីទាំងពីរ។ *ចំណុចសំខាន់ គឺមិនបង្ខំឱ្យភាគីវិវាទខាងណាម្នាក់*អោយផ្សះផ្សាគ្នានៅក្នុងវគ្គនៃការ*សម្រុះសម្រួល ដើម្បីឱ្យបានរបាយការណ៍មួយស្តីពីការផ្សះផ្សាដែលប្រកបដោយជោគជ័យ*។ ការផ្សះផ្សាដោយការបង្ខិតបង្ខំ ពុំមែនជាការបំពេញបំណងនរណាម្នាក់ទេ សមាជិកគណៈកម្មាធិការ ជានិច្ចកាលគួរតែធ្វើឱ្យប្រាកដថា ពួកគេធ្វើការដើម្បីប្រយោជន៍សំខាន់បំផុតដល់អ្នកដែលស្វែងរកសេវាសម្រុះសម្រួលពីគណៈកម្មាធិការដោះស្រាយទំនាស់ថ្នាក់មូលដ្ឋាន។

ដើម្បីធ្វើការងារនោះបាន មានបទដ្ឋានគំរូជាច្រើននៃសេចក្តីសុច្ចរិត ដែលនឹងអាចឆ្លើយតបទៅនឹងគោលការណ៍ទាំងនេះ។ សមាជិកគណៈកម្មាធិការ គួរតែអានគោលការណ៍នេះដោយប្រុងប្រយ័ត្ន ហើយចាត់ទុកវាជាចំណុចសំខាន់ និងរួមបញ្ចូលបទដ្ឋានទាំងនេះទៅក្នុងគោលការណ៍ និងក្រមសីលធម៌នៅក្នុងតួនាទីដែលប្រកបដោយវិជ្ជាជីវៈក្នុងនាមជាសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់។

## ចំណុចទាំងនេះ រួមបញ្ចូល៖



*ការមិនប្រកាន់បក្សពួក* គឺជាសេរីភាព ដែលអាចគេចផុតពីភាពលម្អៀងឬការបំពេញបំណងនរណាម្នាក់ ទោះបីជាការប្រើពាក្យសម្តី ឬសកម្មភាព។ ការមិនប្រកាន់បក្សពួក អាចនាំមកនូវការប្តេជ្ញាចិត្តមួយ ដែលអាចជួយដល់ភាគីទំនាស់ទាំងអស់ ទោះជាប្រឆាំងទៅភាគីតែមួយ អាចនាំឱ្យទទួលបាននូវកិច្ចព្រមព្រៀងមួយ ដែលមានការពេញចិត្តគ្នាទៅវិញទៅមក។ ការមិនប្រកាន់បក្សពួក គឺមានន័យថា អ្នកសម្រុះសម្រួលមិនដើរតួនាទីជាតួបដិបក្សនៅក្នុងដំណើរការនៃការដោះស្រាយទំនាស់[៥]។

*ការរក្សាភាពសម្ងាត់* ត្រូវធានាថា ព័ត៌មានដែលបានទទួលដោយអ្នកសម្រុះសម្រួល ត្រូវបានលាក់ទុកជាអាថ៌កំបាំងធ្វើឡើងក្នុងលក្ខណៈឯកជន ការប្រជុំសម្ងាត់ ឬការប្រជុំរួមគ្នាជាមួយអ្នកដែលមានទំនាស់ត្រូវរក្សាការសម្ងាត់ ហើយមិនត្រូវយកមកបង្ហាញប្រាប់ដល់ភាគី ដែលពុំទាន់មានពាក់ព័ន្ធនឹងការចរចាទេ[៦]។

គួរកត់សម្គាល់ថា ចំពោះទំនាស់រវាងប្តីប្រពន្ធការសម្រុះសម្រួលខុសគ្នាពីការផ្សះផ្សាដែលមានគោលដៅគឺបង្រួបបង្រួមភាគីទំនាស់ទាំងពីរ។ ដោយឡែក ការសម្រុះសម្រួល គឺមានបំណងស្វែងរកការយល់ព្រមទៅវិញទៅមកចំពោះដំណោះស្រាយ ដែលប្រកបដោយការស្ដាប់នាសម្រាប់ក្រុមគ្រួសារដែលត្រូវការជំនួយ។ *ហេតុនេះលទ្ធផលនៃការសម្រុះសម្រួលអាចជាការបែងចែកនៅផ្សេងពីគ្នា ការលែងលះគ្នា ឬក៏ការរក្សាចំណងអាពាហ៍ពិពាហ៍ ដោយរស់នៅជាមួយគ្នាជាប្តីប្រពន្ធ*[៧]។

ពុំមានវិធីសាស្ត្រណាមួយ ដែលអាចដោះស្រាយបាននៅគ្រប់ប្រភេទនៃទំនាស់ទាំងអស់នោះទេ ពីព្រោះមានឧបសគ្គជាច្រើនដែលរាំងស្ទះដល់ការសម្រុះសម្រួលទំនាស់ ហើយវាខុសគ្នាយ៉ាងខ្លាំងពីករណីមួយទៅករណីមួយទៀត។

- ចំណុចសំខាន់នៃការអនុវត្តក្នុងភាពអព្យាក្រឹត្យ (វាជាលក្ខណៈធម្មជាតិ ដែលអ្នកសម្រុះសម្រួលអាចមាន ទស្សនៈផ្ទាល់ខ្លួនអំពីទំនាស់ ប៉ុន្តែគេត្រូវតែធ្វើឱ្យប្រាកដថា គេនឹងមិនផ្តល់នូវគំនិតយោបល់ទៅភាគីដែលពាក់ព័ន្ធនៅក្នុងការសម្រុះសម្រួល បើមិនដូច្នោះទេ ភាគីទំនាស់នឹងមិនទទួលយកនូវដំបូន្មាន ឬក៏ជំនួយពីអ្នកសម្រុះសម្រួល)។

---

[៥] *Moor, C, ដំណើរការនៃការសម្រុះសម្រួល ៖ យុទ្ធសាស្ត្រជាក់ស្តែងសម្រាប់ការដោះស្រាយទំនាស់ ទំព័រ ៣០២*

[៦] *ឯកសារដដែល*

[៧] *ក្រសួងកិច្ចការនារី "សេចក្តីពន្យល់នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ៖ ប្រវត្តិ ទស្សនៈ និងគោលការណ៍សម្រាប់ការបកស្រាយ" ២០០៧ ទំព័រ ១៧៦*

- មិនត្រូវធ្វើ *មជ្ឈត្តកម្ម* ទៅលើសំណុំរឿងទំនាស់ (អ្នកមិនត្រូវប្រកាន់យកតួនាទីជាអ្នកធ្វើសេចក្ដីសម្រេចដោយខ្លួនឯងចំពោះករណីទំនាស់នេះ។ ដូចនេះ លោក អ្នកមិនត្រូវ : ស្ដាប់នូវបញ្ហា រួចធ្វើសេចក្ដីសម្រេចថា តើនរណាត្រូវ ឬក៏គិតនូវអ្វីដែលតុលាការគួរធ្វើយ៉ាងណាជាមួយនឹងករណីនេះទេ។ ភាគីទំនាស់ ប្រហែលជាអាចនឹងគិតថា តួនាទីរបស់អ្នក គឺស្របច្បាប់ ឬជាតួនាទីជាអ្នកសម្រេចបញ្ចប់ទំនាស់ ហើយវានឹងអាចធ្វើឱ្យបាត់បង់ឱកាសសម្រាប់ភាគីទំនាស់ធ្វើការចរចានៅពេលអនាគត។ ការធ្វើរបៀបនេះ ប្រហែលជាមិនអាចជួយឱ្យដំណើរការចរចាប្រព្រឹត្តទៅបានទេ។)
- មិនត្រូវបង្ហាញពីភាពឆេវឆាវ ថ្វីត្បិតតែអ្នកនឹងអាចឃើញថា លទ្ធផលនៃការពិភាក្សារវាងភាគីទាំងពីរ ជិតបានឈានទៅរកលទ្ធផលវិជ្ជមាន ហើយអ្នកមិនត្រូវប្រកាន់ចិត្តឆេវឆាវទេ អ្នកត្រូវតែគ្រប់គ្រងអារម្មណ៍អ្នកឱ្យបានត្រឹមត្រូវ។
- មិនត្រូវដាក់សម្ពាធទៅភាគីទាំងពីរឱ្យឆាប់ឈានទៅរកដំណោះស្រាយមួយ ក្នុងការកំណត់ពេលវេលានៃការពិនិត្យមើលចំពោះករណីនោះ។
- មុននឹងចាប់ផ្ដើមសមាជិកគណៈកម្មាធិការត្រូវពិនិត្យមើលថា ការចូលរួមនៃភាគីដែលពាក់ព័ន្ធត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត។ ការស្ម័គ្រចិត្ត គឺសំដៅទៅលើការចូលរួមជ្រើសរើសដោយសេរី និងការជ្រើសរើសកំណត់សកម្មភាពដោយសេរីដែរ។
- ត្រូវតែស្វែងយល់ពីទំនាក់ទំនងអំណាចរវាងភាគីទំនាស់ ឧទាហរណ៍ ចំពោះករណីដែលពាក់ព័ន្ធរវាងស្ត្រីម្នាក់ និងបុរសម្នាក់ មន្ត្រីរដ្ឋាភិបាលម្នាក់ និងអ្នកភូមិម្នាក់ អ្នកមាន និងអ្នកក្រ ក្មេង និងចាស់ ។ល។ អ្នកមិនអាច ប៉ាន់ស្មានថា ភាគីទំនាស់ដែលបានចូលមករកសេវារបស់គណៈកម្មាធិការ មានអំណាច និងមានឥទ្ធិពលស្មើ គ្នានោះទេ។
- ត្រូវចៀសវាងការប្រើពាក្យបច្ចេកទេសច្បាប់ ឬតុលាការច្រើនពេក។ ការសម្រុះសម្រួល គឺជាដំណើរការមួយ ដែលមានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីប្រព័ន្ធតុលាការ ដែលមានលក្ខណៈផ្លូវការ និងស្របតាមផ្លូវច្បាប់។ វាមានសារសំខាន់ណាស់ ដែលអ្នកចូលរួមទទួលយកការសម្រុះសម្រួលនៅគណៈកម្មាធិការ ដោយពុំមានអារម្មណ៍ថា ត្រូវបានកាត់ក្ដី ឬរាំងស្ទះដោយសារបែបបទផ្លូវការ និងស្របច្បាប់នោះទេ។ យើងមិនត្រូវចាត់ទុកអ្នកមករកសេវាជាដើមបណ្ដឹង ឬចុងចម្លើយទេ ឬក៏អ្នកប្រកាន់តួនាទីដូចជាចៅក្រមក៏ទេដែរ។





*ការសម្រុះសម្រួលមិនដូចតុលាការ និងមិនមានចៅក្រមទេ*

## ៦.៣. កំហុសឆ្គងសាមញ្ញៗដែលត្រូវចៀសវាង[៨]

- ការសន្មតថា ភាគីពាក់ព័ន្ធយល់ច្បាស់ហើយពីដំណើរការនៃការសម្រុះសម្រួល និងបទបញ្ជាផ្ទៃក្នុងនៅពេលសម្រុះសម្រួល
- ការរំលងដំណាក់កាលចាប់ផ្ដើមដំបូង ហើយឈានចូលទៅដំណាក់កាលចរចាផ្ទាល់តែម្ដង ដោយពុំបានទុកឱកាសអោយភាគីទាំងសងខាងបានបន្ធូរអារម្មណ៍ ហើយប្រាប់ពីដំណើររឿងនៅចំពោះមុខគ្នាទៅវិញទៅមក
- ការបង្ហាញពីការមិនពេញចិត្ត ឬការជំទាស់ទៅនឹងជំហរខ្លាំងក្លា ដែលភាគីទំនាស់បានសម្ដែងចេញមកក្នុងពេលចាប់ផ្ដើមដំណើរការដោះស្រាយជម្លោះ
- ការសួរសំណួរដែលមានលក្ខណៈជាការវិនិច្ឆ័យ ឬសំណួរ ដែលមានលក្ខណៈសួរចំៗទៅលើភាគីណាមួយ ជាពិសេស ដោយបង្កអោយមានជាបញ្ហាថ្មីៗមកថែមទៀត ដែលភាគីទំនាស់មិនបាននិយាយចេញនៅពេលពួកគេបង្ហាញយោបល់ ឬក៏ផ្ដល់នូវទម្រង់ ឬភាពលំអៀងនៃដំណើរការដោះស្រាយជម្លោះ ។ បញ្ហាទាំងអស់នេះ អាចនាំអោយភាគីទំនាស់សន្មតថា អ្នកសម្រុះសម្រួលមានភាពលំអៀង ។
- ការបង្ហាញពីភាពមិនអត់ធ្មត់ ឬការមិនសប្បាយចិត្ត ដែលបានសម្ដែងតាមរយៈទំនាក់ទំនងដែលមិនប្រើពាក្យសម្ដី ឬក៏ការសម្ដែងឃ្លាប្រយោគផ្សេងៗ សកម្មភាពនេះនឹងអាចធ្វើឱ្យមានការបង្ខិតបង្ខំដែលធ្វើឱ្យភាគីម្ខាងងាកទៅរកកិច្ចព្រមព្រៀងណាមួយ ។
- ការដាក់សម្ពាធដល់ភាគីទំនាស់ ដើម្បីឱ្យបានទទួលយកនូវដំណោះស្រាយណាមួយ ដើម្បីឱ្យអ្នកអាចបញ្ចប់ករណីដោយជោគជ័យ ។
- អនុញ្ញាតឱ្យភាគីខាងក្រៅ ដែលប្រហែលជាមានភាពជិតស្និទ្ធនឹងភាគីដែលមានទំនាស់ ឧទាហរណ៍ដូចជាសមាជិកដទៃទៀតនៅក្នុងគ្រួសារ អ្នកតំណាងផ្នែកច្បាប់ អ្នកដែលមានឥទ្ធិពល ឱ្យមានវត្តមានក្នុងកំឡុងពេលធ្វើការសម្រុះសម្រួល ។
- ផ្ដល់ការផ្ដោតយកចិត្តទុកដាក់ថែមទៀត ដល់ភាគីដែលនិយាយច្រើនជាងគេនៅក្នុងតួនាទីជាអ្នកសម្រុះសម្រួល សមាជិកគណៈកម្មាធិការ គួរតែត្រួតពិនិត្យឱ្យបានត្រឹមត្រូវយ៉ាងសំខាន់ចំពោះការលំបាកនៃការចរចា និងជំហាន ដែលបានអនុវត្តនៅក្នុងការដោះស្រាយបញ្ហា ព្រមទាំងឆ្លើយតបទៅនឹងប្រភេទទំនាស់ដែលជាក់លាក់ ។

ក្នុងឋានៈជាអ្នកសម្រុះសម្រួល សមាជិកគណៈកម្មាធិការគួរធ្វើការត្រួតពិនិត្យយ៉ាងម៉ត់ចត់ទៅលើដំណើរការចរចា និងជំហាន ដែលត្រូវអនុវត្តនៅក្នុងការដោះស្រាយបញ្ហា និងបង្ហាញពីប្រភេទជាក់លាក់នៃទំនាស់ ។

[៨] *Golann, D, ការសម្រុះសម្រួលវិវាទផ្នែកច្បាប់*

# ៦.៤. យុទ្ធសាស្ត្រការពារការកើនឡើងនៃទំនាស់រវាងភាគី

## តើភាគីទំនាស់ទាំងពីរចង់បានអ្វី ?

គួរផ្តោតទៅលើប្រយោជន៍សាមញ្ញៗរបស់ភាគីជាជាងផ្តោតទៅលើតែជំហររបស់ពួកគេ។ អ្វីដែលមានតម្លៃ គឺការព្យាយាមសួរសំនួរទៅភាគីទំនាស់ ដើម្បីរកមើលគន្លឹះអ្វី ដែលនាំបណ្តាលអោយពួកគេមានជំហរបែបនេះ?

ឧទាហរណ៍ :

ជម្លោះមួយបានកើតឡើងរវាងអ្នកជួលផ្ទះ និងម្ចាស់ផ្ទះ។ អ្នកជួលមិនព្រមបង់ថ្លៃជួលដែលតម្លើងថ្លៃឈ្នួលតាមការសុំរបស់ម្ចាស់ផ្ទះទេ។ ភាគីទាំងពីរមិនព្រមផ្លាស់ប្តូរជំហររបស់ពួកគេទេ ហើយស្ថានភាពនេះនាំទៅរកភាពទាល់ច្រក។ ប្រសិនបើយើងរកមើលហេតុផលដែលនៅពីក្រោយជំហរនោះ យើងអាចចាប់ផ្តើមយល់អំពីប្រយោជន៍របស់ពួកគេទាំងពីរ។ ម្ចាស់ផ្ទះចង់តម្លើងថ្លៃជួលផ្ទះ ពីព្រោះរយៈពេល ៣ ឆ្នាំកន្លងមកនេះ គាត់មិនមានការងារធ្វើទេ។ អ្នកជួលមានអារម្មណ៍ថា ផ្ទះនេះមានការខូចខាតច្រើន ប៉ុន្តែម្ចាស់ផ្ទះមិនបានជួសជុលទេ ដោយសារមូលហេតុនេះហើយ ទើបគាត់មិនចង់បង់ការតម្លើងថ្លៃឈ្នួលផ្ទះ។ ដោយការផ្តោតទៅលើសេចក្តីបារម្ភរបស់ភាគីទាំងពីរ និងប្រយោជន៍របស់ពួកគេនៅក្នុងស្ថានភាពនេះ អ្នកសម្រុះសម្រួលអាចផ្តើមសំនួរទៅរកភាគីទាំងពីរ អំពីអ្វីដែលជាដំណោះស្រាយ។ សន្មតថា ពួកគេទាំងពីរចង់បន្តការជួលទៀត ពួកគេអាចយល់អំពីផលប្រយោជន៍របស់គ្នាទៅវិញទៅមក ដោយម្ចាស់ផ្ទះយល់ព្រមជួសជុលផ្ទះ ហើយអ្នកជួលយល់ព្រមការតម្លើងថ្លៃ។ ស្ថានភាពបែបនេះ ហើយដែលអ្នកសម្រុះសម្រួល អាចជួយបើកផ្លូវសម្រាប់ភាគីទាំងពីរដើរទៅរកការយល់អំពីផលប្រយោជន៍របស់ពួកគេទៅវិញទៅមក។

នេះ គឺជាកតព្វកិច្ចរបស់អ្នកសម្រុះសម្រួល ដែលធ្វើការជាមួយសំណុំរឿងដែលប្តឹងមកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ និងធ្វើការកំណត់នូវសមត្ថភាពផ្នែកវិជ្ជាជីវៈ ដើម្បីជីកកកាយរកមើលផល-ប្រយោជន៍របស់ភាគីទំនាស់ដែលបង្កប់ និងកំណត់អំពីរបៀបដែលអ្នកសម្រុះសម្រួលអាចជួយភាគី ដើម្បីឈានទៅរកការព្រមព្រៀងគ្នា ដែលផលប្រយោជន៍របស់ពួកគេត្រូវបានបំពេញ។

សូមមេត្តាចៀសវាងធ្វើការកាត់សេចក្តីដោយអត្តនោម័ត ទៅលើសំណុំរឿងរបស់ភាគីទំនាស់ដែលប្តឹងមកអ្នក។ ក្នុងឋានៈជាអ្នកសម្រុះសម្រួល មិនមានតួនាទីអ្វីដែលត្រូវរកមើលចំណុច ដើម្បីដាក់កុំសទៅលើភាគីណាមួយនៅក្នុងជម្លោះនេះទេឬត្រូវកំណត់ថាអ្នកនេះខុសអ្នកនោះត្រូវដែរ។សារៈសំខាន់របស់អ្នកសម្រុះសម្រួល គឺការប្រកាន់ជំហរមិនលម្អៀង ហើយភាគីទំនាស់មានការទុកចិត្តមកលើអ្នកដែលជួយពួកគេ ដើម្បីអាចមើលឃើញនូវផលប្រយោជន៍របស់ពួកគេទៅវិញទៅមក ដោយពុំមានការចូលជាមួយភាគីខាងណាមួយ។

# ៦.៥. ជំនាញផ្សេងៗដែលជាគន្លឹះសម្រាប់ការសម្របសម្រួល[១០]

ការស្តាប់ដោយសកម្ម :

ការស្តាប់ដោយយកចិត្តទុកដាក់ចំពោះអ្នកចូលរួមទាំងអស់ និងសួរសំណួរបើក ទើបអាចលើកទឹកចិត្តអ្នកចូលរួមឱ្យបន្តការពិភាក្សារបស់ពួកគេ។ សូមយកចិត្តទុកដាក់ចំពោះកាយវិការ ដែលមិនមែនជាភាសានិយាយ ដូចជា ការសម្តែងទឹកមុខ និងកាយវិការជាដើម។

*ការសួរសំណួរបើក :*

សំណួរបើក អាចនាំឱ្យមានការឆ្លុះបញ្ចាំង និងលើកទឹកចិត្តអ្នកចូលរួមឱ្យនិយាយ។ សំណួរដែលសួរថា "តើអ្នកយល់យ៉ាងដូចម្តេចដែរអំពី...ហេតុអ្វី...? ដូចម្តេច...? ចុះប្រសិនបើ...? ។ល។" វានឹងអាចនាំមកនូវចម្លើយជាច្រើន ដែលពោរពេញទៅដោយការគិតគូរពិចារណាច្រើនជាងសួរសំណួរបិទ ដែលតម្រូវឱ្យមានចម្លើយយ៉ាងសង្ខេប និងជាក់លាក់។

*ការបរប្រយោគយោបល់របស់អ្នកចូលរួម :*

ការប្រើពាក្យដដែលនៃយោបល់អ្នកចូលរួមឡើងវិញ អាចនាំឱ្យអ្នកបានស្រាយបំភ្លឺឡើងវិញថា តើគេបានយល់នូវអ្វីដែលបាននិយាយ និងបញ្ជាក់ឡើងវិញពីចំណុចសំខាន់ៗ ដែលបានលើកឡើងដោយអ្នកចូលរួម។

*ការធ្វើឱ្យមានការចូលរួមស្មើៗគ្នា*

នៅក្នុងដំណើរការសម្រុះសម្រួល ភាគីម្ខាងអាចនិយាយតិច ឬច្រើនជាងភាគីម្ខាងទៀត។ នៅពេលអនុវត្តការងារសម្រុះសម្រួល សូមមេត្តាប្រុងប្រយ័ត្នចំពោះកត្តាផ្សេងៗទៀត ដូចជា ភាពជឿជាក់លើខ្លួនឯង អាយុ ភេទ ឋានៈខុសគ្នា។ សួរអ្នកចូលរួមដែលស្ថិតក្នុងលំដាប់ខ្ពស់ជាងភាគីម្ខាងទៀតឱ្យផ្អាកនិយាយសិន ហើយក្នុងពេលនេះ ត្រូវផ្តល់ឱកាសឱ្យភាគីដែលពុំសូវបាននិយាយ ដើម្បីឱ្យគេមានឱកាសនិយាយម្តង។

*សង្ខេបការពិភាក្សា :*

នៅចុងបញ្ចប់នៃដំណើរការ ត្រូវពិនិត្យចំណុចសំខាន់ៗ និយាយឡើងវិញនូវការសម្រេចទាំងឡាយណាដែលបានអនុម័ត ហើយដែលត្រូវការបញ្ជាក់ឡើងវិញ។ វាមានប្រយោជន៍ក្នុងការប្រើឃ្លាខ្លះ ដូចជា "ប្រសិនបើខ្ញុំយល់ច្បាស់ពីអ្វីដែលអ្នកកំពុងនិយាយ ខ្ញុំជឿជាក់ថា .... "។

*ប្រកាន់ភាពរាក់ទាក់ :*

ឆ្លើយតបចំពោះការនិយាយរបស់អ្នកដទៃ ហើយងក់ក្បាលរក្សាទំនាក់ទំនង ដោយសម្លឹងមុខគ្នាទៅវិញទៅមក ឬញញឹម ព្រោះការធ្វើបែបនេះ វាអាចបង្ហាញថា អ្នកកំពុងស្តាប់ដោយយកចិត្តទុកដាក់។

ប្រការដែលសមាជិកគណៈកម្មាធិការ ដែលជាអ្នកសម្រុះសម្រួលមិនត្រូវអនុវត្តន៍ :

- គ្របសង្កត់មកលើការពិភាក្សា
- ធ្វើការសម្រេចចិត្តក្រោយពេលបានស្តាប់ឮរឿងរ៉ាវទំនាស់របស់ភាគី
- កំណត់ភាគីណាមួយ ដើម្បីដាក់កំហុស ឬចូលខាងភាគីណាមួយ
- អនុញ្ញាតអោយភាគីទី ៣ ចូលពាក់ព័ន្ធជាមួយដំណើរការសម្រុះសម្រួល ឬចូលមកសង្កេត

[១០] *សៀវភៅណែនាំ CRS/Philippines "Panagtago sa Kalinaw" សៀវភៅណែនាំជាមូលដ្ឋានឆ្ពោះទៅរកវប្បធម៌សន្តិភាពសម្រាប់សហគមន៍ Mindanao ។*

## ៦.៦. ការប្រឈមមុខចម្បងៗក្នុងការសម្រុះសម្រួលរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

ដោយហេតុថា ការសម្រុះសម្រួល គឺជាការស្ម័គ្រចិត្ត ភាគីដែលពាក់ព័ន្ធទាំងពីរត្រូវតែយល់ព្រមចំពោះវិធីសាស្ត្រនៃការដោះស្រាយទំនាស់របស់ពួកគេ។ ភាគីម្ខាងមិនអាចបង្ខំឱ្យភាគីម្ខាងទៀត ទទួលយកការសម្រុះសម្រួលទេ។ ទាំងនេះជាការប្រឈមមុខដែលសមាជិកគណៈកម្មាធិការ ត្រូវតែជួបប្រទះជាញឹកញាប់ ហើយជាញឹកញាប់ដែរ អ្នកដែលទាក់ទងនៅក្នុងករណីទំនាស់នឹងមិនឆ្លើយតបចំពោះការអញ្ជើញឱ្យចូលរួមក្នុងការសម្រុះសម្រួលដែរ។ ក្នុងករណីនេះ អ្នកមិនអាចបង្ខំតាមកម្លាំងកាយទៅលើភាគីទំនាស់ឱ្យមកចូលរួមក្នុងការសម្រុះសម្រួល វាមានកម្រិតតែមួយយ៉ាងជាក់លាក់ដែលសមាជិកគណៈកម្មាធិការអាចធ្វើ ក្នុងការដឹកនាំភាគីទំនាស់ដើម្បីធ្វើការពិភាក្សា។

*តើសមាជិកគណៈកម្មាធិការអាចធ្វើអ្វីបានខ្លះ ដើម្បីលើកកម្ពស់ក្នុងការផ្តល់ឱកាសឱ្យភាគីទាំងពីរឡើងមកពិភាក្សា ?*

លើកទឹកចិត្តពួកគេដើម្បីឱ្យគេដឹងថា វា គឺជាប្រយោជន៍របស់ពួកគេក្នុងរយៈពេលវែងចំពោះការសម្រុះ-សម្រួល ដើម្បីជាការចំណេញផ្ទាល់របស់គេ។ ប្រសិនបើវាជាការចាប់អារម្មណ៍របស់ភាគីដែលជាប្តី ដើម្បីដោះស្រាយជាមួយភាគីខាងប្រពន្ធ ដើម្បីជៀសវាការលែងលះគ្នា នេះជាឱកាសរបស់ពួកគេហើយ។ ប្រសិនបើមានការឯកភាពគ្នាទាំងសងខាងក្នុងការលែងលះ ចំណុចនេះអាចលើកយកមកពិភាក្សាគ្នាមុននឹងឈានដល់ការឡើងតុលាការ។

### ការប្រឈមមុខផ្សេងទៀត

- តើសមាជិកគណៈកម្មាធិការ អាចធ្វើអ្វីបានទៀតនៅពេលដែលឃើញថា ពិតជាមានអតុល្យភាពនៃអំណាចរវាងភាគីទាំងពីរ? នេះ គឺជាស្ថានភាពដែលលំបាក ជាពិសេស ប្រសិនបើភាគីម្ខាងមានអំណាចផ្នែកនយោបាយ ឬសេដ្ឋកិច្ច គេប្រហែលជាបំភិតបំភ័យភាគីម្ខាងទៀត ឬក៏គិតថាពួកគេជាអ្នក "ឈ្នះ" នៅក្នុងករណីនេះ។ ត្រូវលើកនិយាយហើយនិយាយទៀតថា នៅទីនេះមិនមែនជាកន្លែងតុលាការទេ ហើយការចាប់អារម្មណ៍សំខាន់ គឺដោះស្រាយទំនាស់ក្នុងវិធីមួយដែលភាគីទាំងអស់អាចទទួលយកបាន មិនមែនបង្កើតឱ្យមាន "អ្នកឈ្នះ" ឬ "អ្នកចាញ់" នោះទេ។ ការធ្វើបែបនេះ វាអាចធ្វើឱ្យពួកគេយល់ពីដំណើរការបានច្បាស់ជាងមុន។

- តើសមាជិកគណៈកម្មាធិការអាចធ្វើអ្វីខ្លះបាន ប្រសិនបើភាគីទំនាស់នៅតែទទូចសុំនាំយកមកជាមួយនូវភាគីផ្សេងទៀត (ឧទាហរណ៍ មេធាវី ឬទីប្រឹក្សា) មកចូលរួមដំណើរការសម្រុះសម្រួល? អ្នកត្រូវតែប្រាប់ភាគីទំនាស់នោះថា គណៈកម្មាធិការដោះស្រាយទំនាស់មិនអនុវត្តការងារ ដូចជាតុលាការទេ។ ការងារនេះ មិនត្រូវឱ្យមានភាគីពីក្រៅមកពាក់ព័ន្ធទេ ជាពិសេស មេធាវី ឬបុគ្គលណាផ្សេងទៀត ដែលមានឥទ្ធិពល ដោយចេតនា ឬអចេតនា អាចធ្វើឱ្យកិច្ចប្រឹងប្រែងនៃការសម្រុះ-

សម្រួលរវាងភាគីទាំងពីរប្រព្រឹត្តទៅមិនបានល្អ។ មុននឹងរៀបចំការសម្រុះសម្រួលលើកទី ១ សមាជិកគណៈកម្មាធិការត្រូវធ្វើឱ្យប្រាកដថា ភាគីទំនាស់យល់ថា មានតែភាគីដែលពាក់ព័ន្ធនឹងទំនាស់ដោយផ្ទាល់ ទើបអាចអនុញ្ញាតឱ្យចូលរួមក្នុងដំណើរសម្រុះសម្រួលបាន។ នេះ គឺជាបំណងនៃការធ្វើឱ្យមានភាពទុកចិត្តជាសម្ងាត់ និងមិនប្រកាន់បក្សពួក។

វាជាករណីលើកលែងចំពោះការប្រើភាសាជនជាតិភាគតិច ប្រសិនបើត្រូវការអ្នកបកប្រែ។

## ៦.៧. ក្រមសីលធម៌នៃការសម្រុះសម្រួល



ការផ្តល់សេវាសម្រុះសម្រួលមិនគិតប្រាក់

- អ្នកសម្រុះសម្រួល មិនត្រូវប្រើតួនាទីរបស់ខ្លួន ដើម្បីទទួលផលចំណេញផ្ទាល់ខ្លួន ឬជាការឆក់ឱកាស ឬពាក់ព័ន្ធនឹងការងារ ឬសកម្មភាពនានា ដែលធ្វើឱ្យប៉ះពាល់ដល់ការងារជាអ្នកសម្រុះសម្រួល។
- អ្នកសម្រុះសម្រួល មិនត្រូវទទួលយកថវិកា ឬក៏វត្ថុមានតម្លៃ នៅក្នុងការអនុវត្តការងាររបស់ខ្លួន ឬភ្ជាប់នូវកាតព្វកិច្ចណាមួយដល់ភាគីណា ដែលអាចនាំឱ្យមានការប៉ះពាល់ដល់ភាពមិនលំអៀងនៃការបំពេញការងាររបស់ខ្លួន[១០]។
- អ្នកសម្រុះសម្រួល ត្រូវតែញែកបញ្ហាឱ្យចេញពីមនុស្ស ហើយដឹកនាំការពិភាក្សាឱ្យផ្តោះទៅរកផលប្រយោជន៍ និងជម្រើសនៃការសម្រេចចិត្ត។
- អ្នកសម្រុះសម្រួល ត្រូវតែប្រឹងប្រែងរក្សាឱ្យមានភាពមិនលម្អៀងរាល់ពេលវេលា។

[១០] Moor, C. ដំណើរការសម្រុះសម្រួល ទំព័រ ៣០៥

# ៧ បែបបទនៃការរៀបចំឯកសារ ដើម្បីដំណើរការសម្រុះសម្រួល

*ទោះបីជាដំណើរការនេះ មានលក្ខណៈមិនផ្លូវការច្រើនជាងផ្លូវការស្របច្បាប់ ក៏ការងារនេះត្រូវតែអនុវត្តតាមនូវបែបបទដ៏ជាក់លាក់ ដែលប្រកបដោយវិជ្ជាជីវៈដែលទាក់ទងនឹងចំណុចខ្លះ ដូចជា ការផ្តល់ព័ត៌មានដល់ភាគីអំពីដំណើរការដែលត្រូវអនុវត្ត និងធ្វើកំណត់ហេតុនៃការអនុវត្តការងារនេះ។ ដំណើរការនេះ ត្រូវតែប្រើចំពោះមនុស្សគ្រប់គ្នា និងគ្រប់ករណីទាំងអស់។*

សូមអនុវត្តតាមលេខរៀង និងបែបបទទាំងនេះ ដើម្បីធ្វើការសម្រុះសម្រួល និងតាមមើលជាលំដាប់នូវរាល់ករណីដែលកើតឡើងនៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ :

៧-១. សៀវភៅកត់ត្រាសំណុំរឿងនៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

៧-២. ទម្រង់ពាក្យបណ្តឹងធ្វើឡើងដោយភាគីដើមបណ្តឹងមកគណៈកម្មាធិការដោះស្រាយទំនាស់

៧-៣. ទម្រង់បង្កាន់ដៃទទួលពាក្យបណ្តឹង - គឺជាបង្កាន់ដៃដែលភាគីដើមបណ្តឹងដាក់គណៈកម្មាធិការ

៧-៤. លិខិតជូនដំណឹងរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ - គឺជាលិខិតជូនដំណឹងដល់ភាគីចុងចម្លើយថា ភាគីដើមបណ្តឹងសំណូមពរយកនីតិវិធីសម្រុះសម្រួលទំនាស់ជាមួយគណៈកម្មាធិការ

៧-៥. កិច្ចព្រមព្រៀង ដើម្បីចូលរួមក្នុងការសម្រុះសម្រួលរបស់ភាគីទំនាស់-ចុះហត្ថលេខា ដោយភាគីចុងចម្លើយ

៧-៦. កំណត់ហេតុនៃការសម្រុះសម្រួល

៧-៧. កិច្ចព្រមព្រៀងនៃការសម្រុះសម្រួល (ប្រសិនបើការសម្រុះសម្រួលឈានដល់កិច្ចព្រមព្រៀង)

*កំណត់ចំណាំ: ក្នុងករណីដែលការសម្រុះសម្រួលឈានដល់ការព្រមព្រៀងមួយ ដែលគូភាគីទាំងសងខាងអាចទទួលយកបាន គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ អាចចេញជូននូវលិខិតមួយដែលបញ្ជាក់ពីកិច្ចព្រមព្រៀងរួមរបស់ភាគីវិវាទបាន (សូមមើលនៅកថាខណ្ឌ ៧.៧)។ លិខិតបញ្ជាក់នៃកិច្ចព្រមព្រៀងនោះ ត្រូវធ្វើ ៣ ច្បាប់ ត្រូវប្រគល់ជូនដល់ភាគីជាដើមបណ្តឹង ១ ច្បាប់ និងភាគីចុងចម្លើយ ១ ច្បាប់ និង ១ ច្បាប់ តម្កល់ទុកនៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ជាឯកសារ។*

ខេត្ត : ____________________

ស្រុក : ____________________

ឃុំ សង្កាត់ : ____________________

គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

## ៧.១. សៀវភៅកំណត់ត្រាសំណុំរឿងរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

| លេខយោង | កាលបរិច្ឆេទទទួល | សង្ខេបប្រធានបទនៃសំណុំរឿង | ព័ត៌មាន ដើមបណ្តឹង និងចុងចម្លើយ | | | | | | សមាជិកគណៈកម្មាធិការចុះបញ្ជីសំណុំរឿង | កាលបរិច្ឆេទទទួលដោយប្រធាន | ត្រូវបានជូនដំណឹង | ការសម្រុះសម្រួល | ផ្សេងទៀត : |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ភាគី | ឈ្មោះ | ភូមិ | ឃុំ សង្កាត់ | ស្រុក | ខេត្ត | | | | | |
| | | ដើមបណ្តឹង | | | | | | | | | | | |
| | | ចុងចម្លើយ | | | | | | | | | | | |
| | | ដើមបណ្តឹង | | | | | | | | | | | |
| | | ចុងចម្លើយ | | | | | | | | | | | |
| | | ដើមបណ្តឹង | | | | | | | | | | | |
| | | ចុងចម្លើយ | | | | | | | | | | | |

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត : ____________________

ស្រុក : ____________________

ឃុំ សង្កាត់ : ____________________

គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

## ៧.២. ទម្រង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ:____________ភេទ______អាយុ______ឆ្នាំសញ្ជាតិ__________

ទីលំនៅបច្ចុប្បន្ន: ភូមិ__________ឃុំ/សង្កាត់__________ ស្រុក/ខណ្ឌ__________

មុខរបរ : ____________________

### សូមគោរពជូនចំពោះ

លោកប្រធានគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ____________________

កម្មវត្ថុ: ប្តឹងទាមទារ____________________

មានទំនាស់ជាមួយ : ពីឈ្មោះ __________ភេទ ________អាយុ ________ឆ្នាំ សញ្ជាតិ__________

ទីលំនៅបច្ចុប្បន្ន : ____________________

ភូមិ__________ឃុំ/សង្កាត់__________ស្រុក/ខណ្ឌ__________ខេត្ត/រាជធានី __________

តបតាមកម្មវត្ថុខាងលើ នាងខ្ញុំ/ខ្ញុំបាទ ____________________

____________________

____________________

អាស្រ័យហេតុនេះ ដូចបានជម្រាបជូនខាងនេះ សូមលោកប្រធានមេត្តាជួយដោះស្រាយអោយនាងខ្ញុំ/ខ្ញុំបាទ ដោយក្តីអនុគ្រោះ ដោយនាងខ្ញុំ/ខ្ញុំបាទយល់ព្រមថា :

- រាល់ព័ត៌មានទាំងឡាយក្នុងដំណើរការសម្រុះសម្រួលទាំងមូលទុកជាការសម្ងាត់ និងមិនអាចប្រើធ្វើជាភស្តុតាងដាក់នៅក្នុងតុលាការទេ។
- ខ្ញុំអាចជ្រើសរើសអ្នកសម្រុះសម្រួលចេញពីគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ដើម្បីធ្វើការសម្រុះ-សម្រួលសំណុំរឿងរបស់ខ្ញុំ។
- នីតិវិធីសម្រុះសម្រួលនេះ គឺដោយការស្ម័គ្រចិត្តមួយរយភាគរយរបស់ភាគីទំនាស់ទាំងពីរ ហើយអាចបញ្ឈប់ដំណើរការនេះគ្រប់ពេលវេលា ទោះជាពុំបានឈានដល់កិច្ចព្រមព្រៀងក៏ដោយ។

សូមលោកប្រធាន ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅអំពីនាងខ្ញុំ/ខ្ញុំបាទ។

ធ្វើនៅ______ ថ្ងៃទី______ ខែ______ ឆ្នាំ______

ស្នាមមេដៃអ្នកប្តឹង

ឈ្មោះ ____________________

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត : ______________________________
ស្រុក : ______________________________
ឃុំ សង្កាត់ : ______________________________
គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

## ៧.៣. ទម្រង់បង្កាន់ដៃទទួលពាក្យបណ្តឹង

បានទទួលពាក្យបណ្តឹងពីឈ្មោះ :____________________ភេទ_______អាយុ______ឆ្នាំ សញ្ជាតិ____________
មុខរបរ : ______________________________________________________________
ទីលំនៅបច្ចុប្បន្ន : ភូមិ_________________________ឃុំ/សង្កាត់ ______________________________
ស្រុក/ខណ្ឌ________________________________ខេត្ត/រាជធានី____________________________________
នៅថ្ងៃទី_______ខែ________ ឆ្នាំ____________ វេលាម៉ោង _________________________________ ។

មានទំនាស់ជាមួយឈ្មោះ : ______________________________________________________

កម្មវត្ថុបណ្តឹង : ______________________________________________________
______________________________________________________________________
______________________________________________________________________
______________________________________________________________________
______________________________________________________________________
______________________________________________________________________
______________________________________________________________________

ធ្វើនៅ_______ ថ្ងៃទី_______ ខែ_______ ឆ្នាំ_______

អ្នកទទួលពាក្យបណ្តឹង

ឈ្មោះ ______________________

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត : ______________________

ស្រុក : ______________________

ឃុំ សង្កាត់ : ______________________

គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

លេខ : ______________

__________ ថ្ងៃទី __________ ខែ __________ ឆ្នាំ __________

## ៧.៤. លិខិតជូនដំណឹងរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

(សម្រាប់ភាគីចុងចម្លើយ)

ប្រធានគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ លោក/លោកស្រី/អ្នកនាងកញ្ញា ឈ្មោះ : ______________

សូមជូនដំណឹងដល់ភាគីចុងចម្លើយ :

លោក/លោកស្រី/កញ្ញា ឈ្មោះ : ______________ ភេទ ________ មុខរបរ ______________

ទីលំនៅបច្ចុប្បន្ន : ភូមិ ______________ ឃុំ/សង្កាត់ ______________ ស្រុក/ខណ្ឌ ______________

ភាគីដើមបណ្ដឹងដែលបានដាក់ពាក្យស្នើសុំធ្វើការសម្រុះសម្រួលវិវាទ :

លោក/លោកស្រី/កញ្ញា ឈ្មោះ : ______________ ភេទ ________ មុខរបរ ______________

ទីលំនៅបច្ចុប្បន្ន : ភូមិ ______________ ឃុំ/សង្កាត់ ______________ ស្រុក/ខណ្ឌ ______________

លិខិតស្នើសុំការសម្រុះសម្រួលដែលបានដាក់មកគណៈកម្មាធិការដោះស្រាយទំនាស់នៅថ្ងៃទីខែឆ្នាំ : __________
សំណុំរឿងដែលបានដាក់មកគណៈកម្មាធិការពាក់ព័ន្ធនឹង :

______________________________________________

______________________________________________

ភាគីដើមបណ្ដឹងបានស្នើសុំឱ្យគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ធ្វើការសម្រុះសម្រួល ។

ក្នុងន័យដូចបានជំរាបជូនខាងលើនេះ ប្រសិនបើលោក លោកស្រី មានបំណងចង់អោយគណៈកម្មការធិការដោះស្រាយធ្វើការសម្រុះសម្រួលទៅលើករណីខាងលើនេះ សូមធ្វើការទំនាក់ទំនងមកគណៈកម្មាធិការដោះស្រាយទំនាស់ក្នុងរយៈពេល ២ ថ្ងៃ បន្ទាប់ពីបានទទួលនូវសេចក្ដីជូនដំណឹងនេះ ។

បានឃើញ និងយល់ព្រម

ថ្ងៃទី ______ ខែ ______ ឆ្នាំ ______

មេឃុំ ចៅសង្កាត់

ប្រធានគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

ឈ្មោះ ______________

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត : ______________________________
ស្រុក : ______________________________
ឃុំ សង្កាត់ : ____________________________
គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

________ថ្ងៃទី ________ខែ________ឆ្នាំ________

## ៧.៥. ទម្រង់នៃកិច្ចព្រមព្រៀងចូលរួមក្នុងការសម្រុះសម្រួល (សម្រាប់ភាគីចុងចម្លើយ)

នាងខ្ញុំ/ខ្ញុំបាទឈ្មោះ :____________________ភេទ______ មុខរបរ ______________________
ទីលំនៅបច្ចុប្បន្ន : ភូមិ______________________ឃុំ/សង្កាត់ ______________________
ស្រុក/ខណ្ឌ______________________________ខេត្ត/រាជធានី______________________

### សូមគោរពជូនចំពោះ

ប្រធានគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ : ________________________________

កម្មវត្ថុ : ការយល់ព្រមឱ្យគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ជួយធ្វើជាអ្នកសម្រុះសម្រួល

យោង : លិខិតជូនដំណឹងលេខ _____ ចុះថ្ងៃទី____ខែ____ឆ្នាំ____ របស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

ដូចដែលមានជំរាបជូនក្នុងកម្មវត្ថុខាងលើ នាងខ្ញុំ/ខ្ញុំបាទ បានយល់ព្រមចូលរួមទៅក្នុងកិច្ចសម្រុះសម្រួលជាមួយភាគីដើមបណ្ដឹង ឈ្មោះ____________________ដែលពាក់ព័ន្ធទៅនឹងករណីនេះ ដោយ នាងខ្ញុំ/ខ្ញុំបាទ យល់ស្របថា :

- រាល់ព័ត៌មានទាំងឡាយក្នុងដំណើរការសម្រុះសម្រួលទាំងមូល ទុកជាការសម្ងាត់ និងមិនអាចប្រើធ្វើជាភស្តុតាងដាក់ទៅក្នុងតុលាការទេ
- ខ្ញុំអាចជ្រើសរើសអ្នកសម្រុះសម្រួលចេញពីគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ដើម្បីធ្វើការសម្រុះ-សម្រួលសំណុំរឿងរបស់ខ្ញុំ
- នីតិវិធីសម្រុះសម្រួលនេះ គឺដោយការស្ម័គ្រចិត្តមួយរយភាគរយរបស់ភាគីទំនាស់ទាំងពីរ ហើយអាចបញ្ឈប់ដំណើរការនេះគ្រប់ពេលវេលា ទោះជាពុំបានឈានដល់កិច្ចព្រមព្រៀងក៏ដោយ ។

នាងខ្ញុំ/ខ្ញុំបាទ បានយល់ព្រមនឹងចូលរួមនៅថ្ងៃទី______ខែ______ឆ្នាំ_______ដើម្បីចូលរួមនៅក្នុងដំណើរការសម្រុះសម្រួលនេះ ។

សូមលោកទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ_______ថ្ងៃទី______ខែ______ ឆ្នាំ_______

ស្នាមមេដៃអ្នកប្ដឹង

ឈ្មោះ______________________

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត : ______________________
ស្រុក : ______________________
ឃុំ សង្កាត់ : ______________________
គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

## ៧.៦. កំណត់ហេតុនៃការសម្រុះសម្រួល

ឆ្នាំ :__________ ខែ__________ ថ្ងៃ __________ ម៉ោង__________ ទីកន្លែង______________________

ការសម្រុះសម្រួលអំពី : ______________________

______________________

______________________

**សមាសភាពចូលរួម :**

១. ______________________
២. ______________________
៣. ______________________
៤. ______________________
៥. ______________________

ព័ត៌មានអំពីភាគី

**ភាគីដើមបណ្តឹង :**

ឈ្មោះ :______________________ ភេទ__________ អាយុ__________ ឆ្នាំ __________

សញ្ជាតិ :__________ សាសនា__________ មុខរបរ ______________________

ទីលំនៅបច្ចុប្បន្ន : ផ្ទះលេខ/ក្រុមទី__________ ភូមិ__________ ឃុំ/សង្កាត់ __________
ស្រុក/ខណ្ឌ______________________ ខេត្ត/រាជធានី ______________________

## ភាគីចុងចម្លើយ :

ឈ្មោះ :________________________ភេទ__________ អាយុ__________ឆ្នាំ__________

សញ្ជាតិ :____________សាសនា____________ មុខរបរ ________________________

ទីលំនៅបច្ចុប្បន្ន : ផ្ទះលេខ/ក្រុមទី__________ភូមិ________________ឃុំ/សង្កាត់ ____________

ស្រុក/ខណ្ឌ________________________ ខេត្ត/រាជធានី ________________

## ដំណើររឿងនៃទំនាស់ :

លទ្ធផលនៃការសម្រុះសម្រួល :

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

ផែនការតាមដាន :

________________________________________

________________________________________

________________________________________

________________________________________

________________________________________

កំណត់ហេតុត្រូវបានបញ្ចប់នៅវេលាម៉ោង ____________________ នាថ្ងៃខែដដែល ។

កំណត់ហេតុត្រូវបានអានឱ្យភាគីទាំងពីរស្តាប់ ហើយភាគីទាំងពីរបានយល់ព្រម ។

អ្នកធ្វើកំណត់ហេតុ

________________

| | ដើមបណ្តឹង | ចុងចម្លើយ | អ្នកសម្រុះសម្រួល/សមាជិកគណៈកម្មាធិការ |
|---|---|---|---|
| ឈ្មោះ | __________ | __________ | __________ |
| ហត្ថលេខា<br>(ឬស្នាមផ្តិតមេដៃ) | __________ | __________ | __________ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត : ____________________
ស្រុក : ____________________
ឃុំ សង្កាត់ : ____________________
គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់
លេខ : __________

## ៧.៧. កិច្ចព្រមព្រៀងនៃការសម្រុះសម្រួល

*រវាង*

ឈ្មោះ :____________ភេទ________អាយុ________ឆ្នាំ សញ្ជាតិ : __________
មុខរបរ : ____________________
ទីលំនៅបច្ចុប្បន្ន : ផ្ទះលេខ/ក្រុមទី/ភូមិ____________ឃុំ/សង្កាត់ ____________
ស្រុក/ក្រុង :____________________ ខេត្ត/រាជធានី : __________

*និង*

ឈ្មោះ :____________ភេទ________អាយុ________ឆ្នាំ សញ្ជាតិ : __________
មុខរបរ : ____________________
ទីលំនៅបច្ចុប្បន្ន : ផ្ទះលេខ/ក្រុមទី/ភូមិ____________ឃុំ/សង្កាត់ ____________
ស្រុក/ក្រុង :____________________ ខេត្ត/រាជធានី : __________

### ១- សំណើរបស់ភាគី :

ក) **ឈ្មោះភាគីដើមបណ្តឹង :** ____________________

____________________

____________________

ខ) **ឈ្មោះភាគីចុងចម្លើយ :** ____________________

____________________

____________________

២- កំឡុងពេលធ្វើការសម្រុះសម្រួល យើងពិភាក្សាអំពី :

_______________________________________________

_______________________________________________

_______________________________________________

៣- លទ្ធផលនៃកិច្ចប្រជុំសម្រុះសម្រួល :

(សូមបញ្ជាក់ថា មិនមានកិច្ចព្រមព្រៀងណាមួយដែលកើតចេញពីការសម្រុះសម្រួល ត្រូវបានចងភ្ជាប់នូវកាតព្វកិច្ចទេ លុះត្រាតែមានចែងយ៉ាងជាក់លាក់ ហើយមានការយល់ព្រមពីភាគីទាំងពីរ) ។

_______________________________________________

_______________________________________________

_______________________________________________

ភាគីទាំងពីរបានយល់ព្រមអនុវត្តកិច្ចព្រមព្រៀងដោយស្ម័គ្រចិត្ត ដូចដែលបានបញ្ជាក់ដោយផ្តិតស្នាមមេដៃរបស់ពួកគេ បន្ទាប់ពីអានខ្លឹមសារកំណត់ហេតុចុងក្រោយនេះ ។

ថ្ងៃខែឆ្នាំ : _______________________________________________

**អ្នកធ្វើកំណត់ហេតុ**

_______________

ភាគីដើមបណ្តឹង　　ភាគីចុងចម្លើយ　　អ្នកសម្រុះសម្រួល/សមាជិកគណៈកម្មាធិការ

ឈ្មោះ : _______________________________________________

ហត្ថលេខា : _______________________________________________

(ឬស្នាមផ្តិតមេដៃ)

## ៨.១. ទម្រង់ និងខ្លឹមសារនៃការធ្វើរបាយការណ៍

គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ គួរធ្វើរបាយការណ៍អំពីលទ្ធផលការងាររបស់ខ្លួនប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ។ ត្រីមាសទី ១ រាប់ពីថ្ងៃទី ០១ ខែមករា រហូតដល់ថ្ងៃទី ៣១ ខែមីនា ត្រីមាសទី ២ ពីថ្ងៃទី ១ ខែមេសា រហូតដល់ថ្ងៃទី ៣០ ខែមិថុនា ត្រីមាសទី ៣ ពីថ្ងៃទី ១ ខែកក្កដា រហូតដល់ថ្ងៃទី ៣០ ខែកញ្ញា និងត្រីមាសទី ៤ ពីថ្ងៃទី ១ ខែតុលា រហូតដល់ថ្ងៃទី ៣១ ខែធ្នូ។

របាយការណ៍ គួរមានជារបាយការណ៍ស្ថិតិតួលេខ និងរបាយការណ៍ពិពណ៌នា។

## ៨.២. របាយការណ៍ស្ថិតិតួលេខ

ស្ថិតិតួលេខនៃសំណុំរឿងដែលបានទទួល និងចាត់ការដោយគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់។ ស្ថិតិតួលេខទាំងនេះ គួរឆ្លុះបញ្ចាំងនូវព័ត៌មានដូចខាងក្រោម :

ក- ចំនួនសំណុំរឿងដែលសល់ពីត្រីមាសមុន។ នេះមានន័យថា វាជាសំណុំរឿង ដែលភាគីទំនាស់មិនទាន់បានអញ្ជើញមកកាន់កិច្ចសម្រុះសម្រួលនៅចំពោះសមាជិកគណៈកម្មាធិការនៅឡើយទេ ហើយកំពុងរង់ចាំ ដើម្បីចូលរួមធ្វើការសម្រុះសម្រួល។

ខ- ចំនួនសំណុំរឿង ដែលបានទទួលក្នុងត្រីមាសបច្ចុប្បន្ន។ សូមធ្វើការរាយការណ៍តែចំនួនតួលេខនៃសំណុំរឿងដែលបានទទួលបានហើយ។

គ- ចំនួនសំណុំរឿងសរុបដែលទុកដោះស្រាយនៅត្រីមាសបច្ចុប្បន្ន។ ចំនួននេះគួរស្មើទៅនឹងចំនួនបូកបញ្ចូលគ្នារវាង ក និង ខ។

ឃ- ចំនួនសំណុំរឿងកំពុងរង់ចាំការសម្រុះសម្រួល។ ចំនួននេះ គួរឆ្លុះបញ្ចាំងនូវចំនួនសំណុំរឿងដែលគណៈកម្មាធិការបានផ្ញើជូនលិខិតអញ្ជើញរួចហើយ ទៅកាន់ភាគីអោយមកចូលរួមក្នុងការសម្រុះសម្រួលនៅចំពោះមុខគណៈកម្មាធិការសម្រុះសម្រួល។

ង- ចំនួនសំណុំរឿងដែលភាគីមួយឬភាគីទាំងពីរបដិសេធមិនព្រមចូលរួមនៅក្នុងការសម្រុះសម្រួល។ នេះមានន័យថា ចុងចម្លើយបដិសេធន៍ ឬខកខានមកបង្ហាញខ្លួននៅគណៈកម្មាធិការ ខណៈដែលកាលបរិច្ឆេទនៃការសម្រុះសម្រួលដែលបានកំណត់រួចហើយនោះបានកន្លងហួសទៅ។ នេះក៏អាចរួមបញ្ចូលផងដែរនូវសំណុំរឿងណា ដែលភាគីទាំងពីរធ្វើការព្យាយាមដោះស្រាយទំនាស់ដោយផ្ទាល់ខ្លួនរបស់ពួកគេ។

ច- ចំនួនសំណុំរឿងដែលភាគីចូលមកធ្វើការសម្រុះសម្រួលដោយគណៈកម្មាធិការដោះស្រាយទំនាស់។

ឆ- ចំនួនសំណុំរឿងដែលបានធ្វើការសម្រុះសម្រួលជោគជ័យដោយគណៈកម្មាធិការ។ ជោគជ័យមានន័យថា ភាគីបានឈានទៅដល់កិច្ចព្រមព្រៀងទាំងស្រុង ឬចំនុចផ្សេងខ្លះទៀតនៃទំនាស់ត្រូវបានទុកសម្រាប់ធ្វើការផ្សះផ្សា។

ជ- ចំនួនសំណុំរឿងដែលការសម្រុះសម្រួលមិនទទួលបានជោគជ័យ។ នេះបង្ហាញពីចំនួនសំណុំរឿងដែលភាគីមិនអាចឈានទៅដល់កិច្ចព្រមព្រៀង។គណៈកម្មាធិការបានព្យាយាមអស់លទ្ធភាពក្នុងការសម្រុះសម្រួល ហើយភាគីនៅតែមិនអាចឈានទៅដល់កិច្ចព្រមព្រៀង។ នៅក្នុងករណីនេះភាគីទំនាស់អាចជ្រើសរើសវិធីផ្សេងក្នុងការដោះស្រាយទំនាស់ ឬផ្តល់ជាសេវាពិគ្រោះយោបល់ផ្នែកច្បាប់ និងចង្អុលបង្ហាញពីនីតិវិធីបន្ត ដូចជា ទៅកាន់ប្រព័ន្ធតុលាការជាដើម។

ខេត្ត : ______________________

ស្រុក : ______________________

ឃុំ សង្កាត់ : ______________________

គណៈកម្មាធិការដោះស្រាយវិវាទាសំរាប់ឃុំ សង្កាត់

# របាយការណ៍ស្ថិតិសំណុំរឿងដែលបានទទួលដោយគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

| ល.រ | ប្រភេទរឿង | សរុបពីមុន | សរុប | មិនទាន់សម្រុះសម្រួល | កំពុងសម្រុះសម្រួល | សម្រុះសម្រួលរួច | | ភាគីមិនយល់ព្រមសម្រុះសម្រួល | បញ្ជូនបណ្ដឹងទៅតុលាការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | សម្រេច | មិនសម្រេច | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

***ការកំណត់សំគាល់សំណុំរឿង និងភាគីបណ្ដឹង***

១. សំណុំរឿងដែលប្ដឹងដោយស្ត្រី = __________ រឿង

២. សំណុំរឿងដែលប្ដឹងដោយបុរស = __________ រឿង

៣. សំណុំរឿងដែលប្ដឹងដោយអ្នកក្រីក្រ (រកចំណូលបានតិចជាង ៥០០០រៀល/ថ្ងៃ) = __________ រឿង

៤. សំណុំរឿងដែលប្ដឹងដោយអនីតិជន (អាយុក្រោម ១៨ ឆ្នាំ) = __________ រឿង

៥. សំណុំរឿងដែលប្ដឹងដោយជនជាតិខ្មែរ = __________ រឿង

៦. សំណុំរឿងដែលប្ដឹងដោយជនជាតិភាគតិច = __________ រឿង

៧. សំណុំរឿងដែលប្ដឹងដោយជនជាតិផ្សេងទៀត = __________ រឿង

# ៨.៣. របាយការណ៍ពិពណ៌នា

ក. គំរូអនុវត្តល្អ

- ផ្តល់ឧទាហរណ៍ទៅលើសំណុំរឿងមួយ ឬពីរ ដែលគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ បានដោះស្រាយដោយជោគជ័យ ។ សូមផ្តល់នូវព័ត៌មានសង្ខេបអំពីសំណុំរឿងនោះ ។
- ធ្វើការពន្យល់ថា កត្តាអ្វីខ្លះដែលគណៈកម្មាធិការដោះស្រាយទំនាស់អាចដោះស្រាយសំណុំរឿងទាំងនោះបានដោយជោគជ័យ ។ឧទាហរណ៍ តើមានជំនាញអ្វីខ្លះដែលអ្នកបានយកមកប្រើប្រាស់នៅក្នុងរឿងនោះ តើមានកត្តាខាងក្រៅអ្វីខ្លះ ដែលជំរុញអោយភាគីទំនាស់ធ្វើការសម្រុះសម្រួល តើភាគីទំនាស់បានទទួលការលើកទឹកចិត្តអ្វីខ្លះ ក្នុងការដោះស្រាយទំនាស់របស់ពួកគេ ។

ខ. ការប្រឈមមុខនានា

- ផ្តល់ឧទាហរណ៍ទៅលើសំណុំរឿងមួយ ឬពីរ ដែលគណៈកម្មាធិការបានដោះស្រាយពុំទទួលបានជោគជ័យ ។ សូមផ្តល់នូវព័ត៌មានសង្ខេបអំពីសំណុំរឿងនោះ ។
- ធ្វើការពន្យល់ថា តើកត្តាអ្វីខ្លះដែលគណៈកម្មាធិការ មិនអាចធ្វើការដោះស្រាយសំណុំរឿងទាំងនោះបានដោយជោគជ័យ ។ ឧទាហរណ៍ តើភាគីទំនាស់មានឥរិយាបទដូចម្តេចខ្លះ នៅក្នុងដំណើរការសម្រុះ-សម្រួលថា តើឋានៈមុខមាត់មិនស្មើគ្នារវាងភាគី បាននាំទៅដល់ភាពបរាជ័យនៃការសម្រុះសម្រួល តើភាគីទំនាស់មានការមិនពេញចិត្តអ្វីខ្លះ ដែលនាំអោយពួកគេដើរចេញពីដំណើរការសម្រុះសម្រួល ។

គ. បញ្ហានានា

សូមផ្តល់នូវបញ្ហានានា ដែលគណៈកម្មាធិការចង់លើកឡើង ដើម្បីស្នើអោយអ្នកគ្រប់គ្រងគម្រោងធ្វើការដោះស្រាយ ។ ព័ត៌មានទាំងនេះ រួមបញ្ចូលនូវបញ្ហានានាដែលទាក់ទិនទៅនឹងបញ្ហារដ្ឋបាល បច្ចេកទេស ឬក៏បញ្ហានានាទាំងឡាយណា ដែលសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ បានជួបប្រទះក្នុងរយៈពេលកន្លងមក ។